# ការសិក្សាស្រាវជ្រាវអំពី

# ប្រាក់ឈ្នួលអប្បបរមាសម្រាប់ឧស្សាហកម្មកាត់ដេរកម្ពុជា

## ថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ២០០៩

រៀបរៀងដោយ :

បណ្ឌិត កង ច័ន្ទតារ៉ាវ័ត្ន

លីវ ដាណែត

វិទ្យាស្ថានកម្ពុជាដើម្បីសិក្សាការអភិវឌ្ឍន៍

គាំទ្រដោយ :

មជ្ឈមណ្ឌលអប់រំច្បាប់សម្រាប់សហគមន៍

# មាតិកា


សេចក្តីថ្លែងអំណរគុណ ៦

ខ្លឹមសារសង្ខេប ៧

ផ្នែកទី ១ : សាវតារនៃគម្រោង ១៤

១. ប្រាក់ឈ្នួលអប្បបរមានៅប្រទេសកម្ពុជា ១៤

២. គោលបំណងនៃការស្រាវជ្រាវ ១៥

៣. ដំណើរការនៃការស្រាវជ្រាវ ១៥

ផ្នែកទី ២ : បែបបទសម្រាប់កំណត់ប្រាក់ឈ្នួលអប្បបរមា ១៧

៤. និយមន័យនៃប្រាក់ឈ្នួលអប្បបរមា ១៧

៥. និន្នាការនៃប្រាក់ឈ្នួលអប្បបរមាក្នុងសកលលោក ១៧

៦. ជំហ៊ាននៃការវិភាគ ២០

៧. គោលបំណងនៃប្រាក់ឈ្នួលអប្បបរមា ២១

៨. កត្តាចាំបាច់ដែលត្រូវដាក់បញ្ចូលក្នុងការគណនាប្រាក់ឈ្នួលអប្បបរមា ២៣

៩. រូបមន្តគណនាប្រាក់ឈ្នួលអប្បបរមា ២៤

ផ្នែកទី ៣ : លទ្ធផលនៃការស្រាវជ្រាវ ២៥

១០. អំពីកម្មករ ២៥

១០.១ សាវតារ ២៥

១០.២ ស្ថានភាពគ្រួសារ ២៦

១០.៣ ស្ថានភាពការងារ ២៧

១១. ហេតុអ្វីបានជាចាំបាច់ត្រូវមានប្រាក់ឈ្នួលអប្បបរមា? (គោលបំណង) ៣០

១២. តើកត្តាអ្វីខ្លះដែលគួរតែត្រូវដាក់បញ្ចូលក្នុងការគណនាប្រាក់ឈ្នួលអប្បបរមា? (កត្តាចាំបាច់) ៣៣

១២.១ កត្តាចាំបាច់ទី ១ : តម្រូវការចាំបាច់របស់កម្មករកាត់ដេរ ៣៣

១២.២ កត្តាចាំបាច់ទី ២ : តម្រូវការចាំបាច់របស់អ្នកក្នុងបន្ទុក ៤៤

១៣. ប្រាក់ឈ្នួលអប្បបរមាត្រឹមត្រូវ ៤៥

១៤. ការពិនិត្យឡើងវិញលើប្រាក់ឈ្នួលអប្បបរមា ៤៧

១៥. ការប្រៀបធៀបប្រាក់ឈ្នួលអប្បបរមាជាមួយនឹងសូចនាករសំខាន់ៗ ៤៨

១៥.១ ខ្សែបន្ទាត់ភាពក្រីក្រ ៤៨

១៥.២ ប្រាក់ឈ្នួលមធ្យម (GDP ម្នាក់ៗ) ៤៩

១៥.៣ តម្លៃបន្ថែមក្នុងកម្មករម្នាក់ៗ ៥១

១៥.៤ កម្លាំងប្រកួតប្រជែង ៥២

ផ្នែកទី ៤ : សេចក្តីសន្និដ្ឋាន និង អនុសាសន៍ ៥៤

ឯកសារពិគ្រោះ ៥៥

## បញ្ជីរូបភាព


រូបភាពទី ១ : ប្រាក់ឈ្នួលអប្បបរមានៅបណ្តាប្រទេសនាំសម្លៀកបំពាក់ចេញសំខាន់ៗ (គិតជា ភភភ4 , ២០០៧) ១៩

រូបភាពទី ២ : ជំហ៊ាននៃការវិភាគនៃការស្រាវជ្រាវ ២១

រូបភាពទី ៣ : រូបមន្តទូទៅសម្រាប់ការគណនាប្រាក់ឈ្នួលអប្បបរមា ២៤

រូបភាពទី ៤ : ទំហំគ្រួសារ ២៧

រូបភាពទី ៥ : ចំនួនកម្មករទៅតាមចំនួនឆ្នាំនៃបទពិសោធន៍ការងារក្នុងរោងចក្របច្ចុប្បន្ន ២៨

រូបភាពទី ៦ : ប្រាក់ឈ្នួលជាក់ស្តែង តាមធាតុផ្សំ ២៩

រូបភាពទី ៧ : ប្រាក់ឈ្នួលជាក់ស្តែងគិតជាតម្លៃបច្ចុប្បន្ន តាមខេត្ត (ដុល្លារក្នុង១ខែ) ៣០

រូបភាពទី ៨ : គោលបំណងតម្រូវឱ្យមានប្រាក់ឈ្នួលអប្បបរមា-តាមការយល់ឃើញរបស់កម្មករកាត់ដេរ ៣០

រូបភាពទី ៩ : តើមានបម្រែបម្រួលនៅក្នុងប្រាក់ថែមម៉ោងក្នុងឆ្នាំ២០០៩ខ្លះទេ? ៣២

រូបភាពទី ១០ : កត្តាចាំបាច់តម្រូវឱ្យដាក់បញ្ចូលក្នុងប្រាក់ឈ្នួលអប្បបរមា ៣៣

រូបភាពទី ១១ : ចំណាយជាមធ្យមលើតម្រូវការចាំបាច់ តាមមុខចំណាយ (ដុល្លារក្នុង១ខែ) ៣៤

រូបភាពទី ១២ : ចំណាយជាមធ្យមលើតម្រូវការចាំបាច់របស់កម្មករ តាមតំបន់ (ដុល្លារក្នុង១ខែ) ៣៥

រូបភាពទី ១៣ : ចំណាយជាមធ្យមលើអាហារ តាមតំបន់ (ដុល្លារក្នុង១ខែ) ៣៦

រូបភាពទី ១៤ : ប្រាក់ឈ្នួលជាក់ស្តែងគិតតាមថ្លៃបច្ចុប្បន្ន និង ចំណាយលើអាហារ តាមតំបន់ (ដុល្លារក្នុង១ខែ) ៣៦

រូបភាពទី ១៥ : ចំណាយជាមធ្យមលើការស្នាក់នៅ តាមតំបន់ (ដុល្លារក្នុង១ខែ) ៣៨

រូបភាពទី ១៦ : ចំណាយជាមធ្យមលើការធ្វើដំណើរ និង ការទំនាក់ទំនង តាមតំបន់ (ដុល្លារក្នុង១ខែ ) ៤០

រូបភាពទី ១៧ : ចំណាយជាមធ្យមលើសម្លៀកបំពាក់ តាមតំបន់ (ដុល្លារក្នុង១ខែ) ៤១

រូបភាពទី ១៨ : ចំណាយជាមធ្យមលើការថែទាំសុខភាព តាមតំបន់ (ដុល្លារក្នុង១ខែ) ៤៣

រូបភាពទី ១៩ : តម្រូវការចាំបាច់របស់អ្នកក្នុងបន្ទុក (ដុល្លារក្នុង១ខែ) ៤៤

រូបភាពទី ២០ : រូបមន្តគណនាប្រាក់ឈ្នួលអប្បបរមា ៤៥

រូបភាពទី ២១ : ប្រាក់ឈ្នួលអប្បបរមាត្រឹមត្រូវ (សេណារីយ៉ូទី ១) ៤៦

រូបភាពទី ២២ : ប្រាក់ឈ្នួលអប្បបរមាត្រឹមត្រូវ (សេណារីយ៉ូទី ២) ៤៧

រូបភាពទី ២៣ : ខ្សែបន្ទាត់ភាពក្រីក្រ និង ប្រាក់ឈ្នួលអប្បបរមា (ក្នុង១ថ្ងៃ-ថ្លៃដុល្លារបច្ចុប្បន្ន) ៤៩

រូបភាពទី ២៤ : ប្រាក់ឈ្នួលអប្បបរមា និង GDPម្នាក់ៗ (ឆ្នាំ២០០៩) ៥០

រូបភាពទី ២៥ : តម្លៃបន្ថែម និង ប្រាក់ឈ្នួលជាក់ស្តែង ក្នុងឧស្សាហកម្មកាត់ដេរ (២០០៤-២០០៩) ៥១

រូបភាពទី ២៦ : ទំហំនៃភាពចំណេញនៅក្នុងឧស្សាហកម្មកាត់ដេរ នៅប្រទេសមួយចំនួន (%) ៥៣

## បញ្ជីតារាង

តារាង ១ : ទំហំសំណាក ១៦

តារាងទី ២ : កម្រិតវប្បធម៌របស់អ្នកត្រូវបានសម្ភាសន៍ ២៥

តារាងទី ៣ : ចំនួនអ្នកត្រូវបានសម្ភាសន៍ដែលជួលបន្ទប់ស្នាក់នៅ ៣៨

តារាងទី ៤ : តើមុខចំណាយលើតម្រូវការចាំបាច់មួយណាដែលសំខាន់បំផុត? ៤៣

## សេចក្តីថ្លែងអំណរគុណ

តាងនាមឱ្យក្រុមសិក្សាស្រាវជ្រាវ ខ្ញុំសូមអរគុណចំពោះអង្គការ Oxfam Novib ដែលបានផ្តល់មូលនិធិ តាមរយៈមជ្ឈមណ្ឌលអប់រំច្បាប់សម្រាប់សហគមន៍ (CLEC) ដល់ការសិក្សាស្រាវជ្រាវដ៏មានសារៈសំខាន់នេះ ជាពិសេសសូមអរគុណចំពោះលោក **មឿន តុលា** ប្រធានកម្មវិធីសិទ្ធិការងារនៅ CLEC ដែលបានផ្តួចផ្តើមគំនិតធ្វើឱ្យគម្រោងនេះដំណើរការដោយរលូន ។

ខ្ញុំក៏សូមអរគុណយ៉ាងជ្រាលជ្រៅបំផុត ចំពោះកម្មករកាត់ដេរទាំងអស់គ្នា ដែលបានចំណាយពេលវេលាដ៏មានតម្លៃព្រមទាំងកម្លាំងកាយនិងចិត្ត ដើម្បីចូលរួមផ្តល់ការសម្ភាសន៍ជាមួយក្រុមស្រាវជ្រាវរបស់យើងខ្ញុំ ក៏ដូចជាការពិភាក្សាជាក្រុមផងដែរ ។ ប្រសិនបើមិនមានកិច្ចសហប្រតិបត្តិការពីអ្នកទាំងអស់គ្នាទេ ការសិក្សាស្រាវជ្រាវនេះពុំអាចដំណើរការទៅបានឡើយ ។

ជាទីបញ្ចប់នេះ ខ្ញុំសូមថ្លែងអំណរគុណជាពិសេសដល់បុគ្គលិក នៃវិទ្យាស្ថានកម្ពុជាដើម្បីសិក្សាការអភិវឌ្ឍន៍ ដែលបានជួយដល់ការងារសិក្សាស្រាវជ្រាវនេះ ដោយមិនគិតពីភាពនឿយហត់ ដែលធ្វើឱ្យគម្រោងនេះសម្រេចជោគជ័យក្នុងរយៈពេលដ៏ខ្លី ព្រមទាំងអរគុណផងដែរដល់អ្នកសម្របសម្រួលនៅមូលដ្ឋាន និង អ្នកបញ្ចូលទិន្នន័យដែលបំពេញការងារយ៉ាងមានប្រសិទ្ធភាព ក្នុងការសិក្សាស្រាវជ្រាវនេះ ។

បណ្ឌិត **កង ច័ន្ទតារ៉ាវ័ត្ត**

ប្រធានក្រុមគម្រោង

នាយកវិទ្យាស្ថានកម្ពុជាដើម្បីសិក្សាការអភិវឌ្ឍន៍ (CIDS)

# ខ្លឹមសារសង្ខេប

## ផ្នែកទី ១ : សាវតារនៃគម្រោង

ឆ្នាំ១៩៩៧ ច្បាប់ការងារកម្ពុជាត្រូវបានអនុម័ត ហើយបានផ្តល់សិទ្ធិដល់ក្រសួងការងារក្នុងការកំណត់កម្រិតប្រាក់ឈ្នួលអប្បបរមាសម្រាប់ការងារគ្រប់វិស័យទាំងអស់ ។ តាំងពីពេលនោះមក មានតែឧស្សាហកម្ម វាយនភ័ណ្ឌ សម្លៀកបំពាក់ និង ស្បែកជើង (និយាយឱ្យខ្លី ឧស្សាហកម្មកាត់ដេរ) ប៉ុណ្ណោះទេ ដែលមានប្រាក់ឈ្នួលអប្បបរមាត្រូវបានកំណត់ស្មើនឹង ៥០ដុល្លារក្នុង១ខែនាបច្ចុប្បន្ន ។ គណៈកម្មាធិការក្រុមប្រឹក្សាការងារ (LAC) នឹងពិនិត្យប្រាក់ឈ្នួលអប្បបរមាឡើងវិញក្នុងឆ្នាំ ២០១០ ។ រហូតមកដល់បច្ចុប្បន្នកាល មិនមានប្រកាសស្តីពីប្រាក់ឈ្នួលអប្បបរមា ហើយក៏មិនមានស្តង់ដារសម្រាប់ការកំណត់កម្រិតសមស្របទេ ។

មជ្ឈមណ្ឌលអប់រំច្បាប់សម្រាប់សហគមន៍ (CLEC) បានស្នើសុំឱ្យវិទ្យាស្ថានកម្ពុជាដើម្បីសិក្សាការអភិវឌ្ឍន៍ (CIDS) ធ្វើការសិក្សាស្រាវជ្រាវ ដើម្បីជាមូលដ្ឋានក្នុងការបង្កើតបែបបទមួយ ប្រកបដោយតម្លាភាព និង ងាយស្រួលក្នុងការកំណត់ *ប្រាក់ឈ្នួលអប្បបរមាត្រឹមត្រូវ* សម្រាប់ឧស្សាហកម្មកាត់ដេរកម្ពុជា ។ ការសិក្សាស្រាវជ្រាវនេះក៏នឹងផ្តល់គុណប្រយោជន៍ដែរ ដល់វិស័យដទៃទៀត ដោយបង្ហាញផ្លូវក្នុងការរៀបចំក្របខ័ណ្ឌបញ្ញត្តិ ស្តីពីប្រាក់ឈ្នួលអប្បបរមា ។ លើសពីនេះទៀត ការសិក្សាស្រាវជ្រាវនេះក៏មានសារៈសំខាន់ សម្រាប់គណៈកម្មាធិការក្រុមប្រឹក្សាការងារផងដែរ ដូចជា ផ្តល់នូវទិន្នន័យថ្មីៗបំផុត និង ការវិភាគអំពីស្ថានភាពកម្មករកាត់ដេរ ។

ការសិក្សាស្រាវជ្រាវនេះផ្អែកលើមូលដ្ឋានបីគឺ : របាយការណ៍ និង ឯកសារអំពីប្រាក់ឈ្នួលអប្បបរមានៅប្រទេសដទៃទៀត បទសម្ភាសន៍ជាមួយកម្មករកាត់ដេរចំនួន៣០០នាក់នៅក្នុងតំបន់ចំនួន៥ (ទីក្រុងភ្នំពេញ ខេត្តកំពង់ឆ្នាំង ខេត្តកណ្តាល ខេត្តព្រះសីហនុ និងខេត្តស្វាយរៀង) និង កិច្ចពិភាក្សាក្រុមគោលដៅជាមួយនឹងកម្មករ កាត់ដេរចំនួន៥០នាក់នៅក្នុងតំបន់ទាំង៥ ។

## ផ្នែកទី ២ : បែបបទនៃការកំណត់ប្រាក់ឈ្នួលអប្បបរមា

ដើម្បីឱ្យមានមូលដ្ឋានរួមក្នុងការចរចាប្រកបដោយប្រសិទ្ធភាព ដំបូងយើងត្រូវដឹងនិយមន័យនៃពាក្យ "ប្រាក់ឈ្នួលអប្បបរមា" ។ ពេលខ្លះ ពាក្យដូចជា "ចំណូលអប្បបរមា" និង "ប្រាក់ឈ្នួលសមរម្យ" ត្រូវបានប្រើច្រឡំជាមួយនឹងពាក្យ

"ប្រាក់ឈ្នួលអប្បបរមា" បើទោះបីអត្ថន័យនៃពាក្យខាងលើនេះខុសគ្នាក៏ដោយ ។ *"ប្រាក់ឈ្នួលអប្បបរមា" ជាប្រាក់ឈ្នួលមួយដែលនិយោជកមិនអាចបន្ទាបកម្រិតវាបាន ហើយកម្រិតរបស់វាត្រូវបានកំណត់ និង ធានាដោយច្បាប់ ។* "ចំណូលអប្បបរមា" ជាកម្រិតចំណូលមួយដែលធានាឱ្យពលរដ្ឋម្នាក់ និងគ្រួសាររបស់គេរស់បាននៅក្នុងសង្គម ដោយមិនអាស្រ័យទៅលើប្រភេទការងាររបស់គេទេ ។ "ប្រាក់ឈ្នួលសមរម្យ" ជាប្រាក់ឈ្នួលមួយដែលមានកម្រិតគ្រប់គ្រាន់សម្រាប់តម្រូវការចាំបាច់របស់កម្មករ និង គ្រួសារ ព្រមទាំងមានសល់សម្រាប់សន្សំដើម្បីអនាគត ។

ក្នុងអំឡុងពេលពីឆ្នាំ ២០០១ ដល់ ២០០៧ ប្រាក់ឈ្នួលអប្បបរមានៅក្នុងពិភពលោកបានកើនឡើងជាមធ្យម ៥,៧% ក្នុង១ឆ្នាំ ដែលក្នុងប្រទេសជឿនលឿនមាន ៣,៨% នៅពេលដែលក្នុងប្រទេសកំពុងអភិវឌ្ឍន៍មាន ៦,៥% ក្នុង១ឆ្នាំ ។ នៅក្នុងប្រទេសទាំងអស់ដែលឈានមុខគេក្នុងការនាំសម្លៀកបំពាក់ចេញ បានអនុវត្តន៍ប្រាក់ឈ្នួលអប្បបរមាសម្រាប់កម្មករកាត់ដេរ ។ គិតជាកម្លាំងទិញនៃប្រាក់ដុល្លារនៅក្នុងប្រទេសអាមេរិក (PPP$) ប្រាក់ឈ្នួលអប្បបរមាមានកម្រិតខ្ពស់បំផុតនៅក្នុងប្រទេសតៃវ៉ាន់ (៩៥៥ PPP$) នៅពេលដែលកម្មករក្នុងប្រទេសបង់ក្លាដេសទទួលបានកម្រិតទាបបំផុត (៦៩ PPP$) ក្នុងឆ្នាំ ២០០៧ ។ កម្រិតប្រាក់ឈ្នួលអប្បបរមានៅប្រទេសកម្ពុជាគឺ ១៥៦ PPP$ ទាបជាងនៅប្រទេសចិនដែលមាន ២០៤ PPP$ ប៉ុន្តែប្រហាក់ប្រហែលគ្នាទៅនឹងប្រទេសឥណ្ឌូនេស៊ី (១៤២ PPP$) និងប្រទេសវៀតណាម (១២០ PPP$) ក្នុងឆ្នាំ ២០០៧ ។

បើទោះបីជាប្រាក់ឈ្នួលអប្បបរមា គឺជាឧបករណ៍ទូទៅសម្រាប់នយោបាយកាត់បន្ថយភាពក្រីក្រក៏ដោយ ក៏មកដល់ពេលនេះនៅមិនទាន់មានស្តង់ដាររួមមួយសម្រាប់គណនាកម្រិតរបស់វាឱ្យបានត្រឹមត្រូវនៅឡើយទេ ។ ប៉ុន្តែ ជាគោលការណ៍រូបមន្តសម្រាប់គណនាត្រូវគិតអំពីគោលបំណង និង លក្ខណៈវិនិច្ឆ័យដែលតម្រូវឱ្យមានប្រាក់ឈ្នួលអប្បបរមា ។

ការសិក្សាស្រាវជ្រាវនេះនឹងបង្ហាញពីរបៀបគណនាប្រាក់ឈ្នួលអប្បបរមាត្រឹមត្រូវមួយ ដោយប្រើវិធីសាស្ត្រជាបីជំហ៊ានគឺ : ១) កំណត់គោលបំណងនៃប្រាក់ឈ្នួលអប្បបរមា ២) កំណត់កត្តាចាំបាច់ទាំងឡាយទៅក្នុងប្រាក់ឈ្នួលអប្បបរមា និង ៣)សម្រួលរូបមន្តគណនាទៅតាមជំហ៊ានទី១ និង ទី២ ។ ជំហ៊ានទី១ និងទី២ ត្រូវតែគិតគូរអំពីស្ថានភាពជាក់ស្តែងរបស់កម្មករ ព្រមទាំងតម្រូវការរបស់គេ ដូច្នេះហើយ ត្រូវពឹងផ្អែកលើការសម្ភាសន៍ និងពិភាក្សាជាមួយក្រុមគោលដៅ ។ តាមរយៈនេះ យើងអាចធានាថា ប្រាក់ឈ្នួលអប្បបរមាដែលរកឃើញ វានឹងត្រឹមត្រូវ ព្រមទាំងឆ្លុះបញ្ចាំងពីតម្រូវការចាំបាច់របស់កម្មករ ។

តាមរយៈឯកសារស្រាវជ្រាវ គោលបំណងរួមរបស់ប្រាក់ឈ្នួលអប្បបរមាមាន : ធានាតម្រូវការចាំបាច់របស់កម្មករ (ពេលខ្លះព្រមទាំងអ្នកក្នុងបន្ទុក), ការពារការធ្លាក់ចុះនៃប្រាក់ឈ្នួល, លើកទឹកចិត្តឱ្យប្រឹងធ្វើការ, និងធ្វើឱ្យមានសមភាពក្នុងការទទួលផលនៃកំណើនសេដ្ឋកិច្ច (សមភាពនៃប្រាក់ចំណូល) ។ ក្រោយពីយើងដឹងអំពីគោលបំណងខាងលើនៃប្រាក់ឈ្នួលអប្បបរមា យើងនឹងកំណត់កត្តាចាំបាច់ទាំងឡាយដែលត្រូវរាប់បញ្ចូលទៅក្នុងកម្រិតរបស់វា ។ ជាទូទៅកត្តាចាំបាច់ទាំងឡាយដែលគេយកមកគិតគឺ : តម្រូវការចាំបាច់របស់កម្មករ (ពេលខ្លះព្រមទាំងអ្នកក្នុងបន្ទុក), កម្រិតទូទៅប្រាក់ឈ្នួល, ប្រព័ន្ធសន្តិសុខសង្គម និង កត្តាសេដ្ឋកិច្ច ដូចជា កម្រិតនៃភាពគ្មានការងារធ្វើ, ផលិតភាពការងារ និង ភាពប្រកួតប្រជែង ។

## ***ផ្នែកទី ៣ : លទ្ធផលនៃការស្រាវជ្រាវ***

អ្នកដែលត្រូវបានសម្ភាសន៍មាន ៩០% ជាស្ត្រីដែលមានអាយុជាមធ្យម២៤ឆ្នាំ ។ គេទាំងនោះភាគច្រើននៅលីវ ហើយជាអ្នករកចំណូលអោយគ្រួសារ ។ ៩៤% នៃកម្មករគឺមិនមានកម្រិតវប្បធម៌លើសពីថ្នាក់ទី៩ឡើយ ។ ស្ទើរតែកម្មករទាំងអស់ដែលនៅក្នុងភ្នំពេញ (៩០%) គឺមកពីខេត្ត ជាពិសេសមកពីព្រៃវែង និង ខេត្តកំពង់ចាម ។ ស្រដៀងគ្នានេះដែរ កម្មករ ៦៧% ធ្វើការនៅក្នុងខេត្តកណ្តាល និង ក្នុងខេត្តព្រះសីហនុ គឺជាកម្មករចំណាកស្រុក ។ ចំណែកឯកម្មករធ្វើការនៅខេត្តស្វាយរៀង និងខេត្តកំពង់ឆ្នាំងគឺជាប្រជាជនក្នុងខេត្ត ។ គ្រួសាររបស់កម្មករកាត់ដេរជាមធ្យមមានសមាជិក ៤នាក់ ដែលក្នុងនោះ២នាក់ជាអ្នករកចំណូលចិញ្ចឹមគ្រួសារ ។ ៦០% នៃ៣០០គ្រួសារ កម្មករដែលយើងបានសម្ភាសន៍មិនមានប្រាក់ចំណូលច្រើនជាង៩០ដុល្លារក្នុង១ខែទេ (ដោយមិនរាប់បញ្ចូលប្រាក់ខែរបស់កម្មករ) ។

កម្មករចំនួនទាំង៣០០នាក់គឺមកពីរោងចក្រចំនួន ៧៤ ។ ភាគច្រើននៃកម្មករទាំងនោះធ្វើការក្នុងផ្នែកដេរ ដែលមានបទពិសោធន៍ការងារក្នុងឧស្សាហកម្មចំនួន៣ឆ្នាំ និង ២,៥ឆ្នាំនៅក្នុងរោងចក្របច្ចុប្បន្ន ។ ៤៥% នៃកម្មករគឺជាសមាជិកនៃសហជីព ។ ជាមធ្យម កម្មកររកចំណូលជាក់ស្តែងបាន ៨៦.៨៨ដុល្លារក្នុង១ខែ ក្នុងរយៈពេលចុងក្រោយនេះ ។ កម្មករនៅក្នុងខេត្តព្រះសីហនុអាចរកបានច្រើនជាងគេបំផុត (៩០.១៧ដុល្លារក្នុង១ខែ) ពេលដែលកម្មករនៅក្នុងខេត្តស្វាយរៀងរកបានតិចជាងគេបំផុត (៨២.៥៦ដុល្លារក្នុង១ខែ) ។ ជាទូទៅ កម្មករដេរស៊ីបុង និង/ឬ ដែលមានថែមម៉ោងច្រើន រកចំណូលបានច្រើនជាងកម្រិតមធ្យមកម្មករទូទៅរកបាន ។

យោងតាមការពិភាក្សាជាក្រុមជាមួយនឹងកម្មករនៅក្នុងខេត្តចំនួន ៥ មានការយល់ឃើញជារួមថា ប្រាក់ឈ្នួលអប្បបរមាពិតជាចាំបាច់ ដើម្បីគោលបំណង២យ៉ាង : ១) ធានាតម្រូវការចាំបាច់របស់កម្មករ និងអ្នកក្នុងបន្ទុក និង ២) ការពារ

ការធ្លាក់ចុះនៃប្រាក់ឈ្នួល ។ ទាក់ទងនឹងគោលបំណងទី១ កម្មករបានបញ្ជាក់ថា កាតព្វកិច្ចចម្បងរបស់គេគឺ ធ្វើការកាត់ដេរ ដើម្បីបានចំណូលជាលុយទៅឱ្យគ្រួសារ ។ ប្រសិនកម្មកររកចំណូលមិនបានគ្រប់គ្រាន់ផ្ញើទៅផ្ទះទេ ឪពុកម្តាយរបស់គេនឹងហៅគេឱ្យត្រឡប់ទៅផ្ទះវិញ ។ *ដូច្នេះ ប្រាក់ឈ្នួលអប្បបរមាត្រូវតែធានាឱ្យបានតម្រូវការចាំបាច់របស់កម្មករ និងអ្នកក្នុងបន្ទុក* ។ ទាក់ទងនឹងគោលបំណងទី២ ប្រាក់ឈ្នួលបច្ចុប្បន្នរបស់កម្មករគឺពឹងផ្អែកទាំងស្រុងទៅលើចំណូលពីម៉ោងថែម ។ នៅពេលដែលសេដ្ឋកិច្ចធ្លាក់ចុះ ដូចបច្ចុប្បន្ននេះ គួបផ្សំនឹងការប្រកួតប្រជែងដ៏តឹងតែងនៅក្នុងឧស្សាហកម្មកាត់ដេរ ការថយចុះនៃប្រាក់ឈ្នួលជាក់ស្តែង ដោយសារការកាត់បន្ថយ ឬ បំបាត់ម៉ោងថែម កម្មករមិនមានលទ្ធភាពក្នុងការដោះស្រាយតម្រូវការចាំបាច់របស់គេនិងអ្នកក្នុងបន្ទុកទេ។ ដើម្បីធានា ដល់ជីវិតការងាររបស់កម្មករ វាជារឿងចាំបាច់បំផុតតម្រូវឱ្យមានប្រាក់ឈ្នួលអប្បបរមាមួយធានាដោយច្បាប់ ដែលជាកម្រិតទាបបំផុតនៃការធ្លាក់ចុះរបស់ប្រាក់ឈ្នួល។

ស្របតាមគោលបំណងទាំងពីរ កម្មករបានទាមទារកត្តាពីរសំខាន់ៗដាក់បញ្ចូលទៅក្នុងការកំណត់ប្រាក់ឈ្នួលអប្បបរមា : ១) តម្រូវការចាំបាច់របស់កម្មករ និង ២) តម្រូវការចាំបាច់របស់អ្នកក្នុងបន្ទុក ។ **កត្តាទាំងពីរនេះត្រូវតែបំពេញឱ្យបានដើម្បីធានាឱ្យមានកម្លាំងពលកម្មគ្រប់ពេលសម្រាប់ឧស្សាហកម្មកាត់ដេរ ដែលជាមូលដ្ឋានដ៏ចាំបាច់សម្រាប់ស្ថេរភាព និងនិរន្តភាព នៃឧស្សាហកម្មកាត់ដេរ ជាពិសេសក្នុងពេលដែលសេដ្ឋកិច្ចកំពុងធ្លាក់ចុះ ។**

តម្រូវការចាំបាច់របស់កម្មករដែលត្រូវបានបង្ហាញនៅក្នុងរបាយការណ៍នេះ គឺផ្អែកលើខ្ទង់ចំណាយបច្ចុប្បន្នរបស់កម្មករលើតម្រូវការចាំបាច់ ប៉ុន្តែវាអាចមិនឆ្លុះបញ្ចាំង ពីតម្រូវការពិតដែលចាំបាច់ សម្រាប់ទ្រទ្រង់សុខភាព ។ ផ្អែកតាមលទ្ធផលនៃការស្រាវជ្រាវនេះ កម្មករចំណាយ ជាមធ្យម៥៦,៩៩ដុល្លារក្នុង១ខែសម្រាប់តម្រូវការចាំបាច់របស់គេ ដែលក្នុងនោះ៣២,៧៩ដុល្លារសម្រាប់អាហារ និង ២៤,២០ដុល្លារ សម្រាប់តម្រូវការចាំបាច់ដទៃទៀតដូចជា សម្រាប់ការស្នាក់នៅ ការធ្វើដំណើរ សម្លៀកបំពាក់ ការថែទាំសុខភាព ។ល។ បើទោះបីតម្រូវការចាំបាច់មានច្រើនប្រភេទក៏ដោយ កម្មករទាំងអស់យល់ឃើញថា ចំណាយទៅលើម្ហូបអាហារជាអាទិភាពទី១ នៅពេលដែលសម្រាប់សុខភាពជាអាទិភាពទី២ ។ ព្រោះគេយល់ថា បើចំណាយសម្រាប់កត្តាទាំងពីរនេះមិនគ្រាន់ទេ នោះគេក៏មិនអាចធ្វើការបានដែរ ។

ក្នុងការគណនាតម្រូវការចាំបាច់នៃអ្នកក្នុងបន្ទុករបស់កម្មករ ក្រុមស្រាវជ្រាវបានផ្អែកទៅលើទឹកប្រាក់ដែលកម្មករចាំបាច់ត្រូវផ្ញើទៅគ្រួសារប្រចាំខែ ។ កម្រិតទាបបំផុតនៃប្រាក់បញ្ញើគឺជាកង្វះខាតរបស់គ្រួសារ ដែលវាជាកាតព្វកិច្ចរបស់កម្មករប្រចាំខែ

សម្រាប់គ្រួសារ ។ ឆ្លងតាមក្រុមពិភាក្សា កម្មករត្រូវតែផ្ញើយ៉ាងហោចណាស់ក៏១៥ដុល្លារក្នុង១ខែដែរ ដើម្បីជួយដោះស្រាយការរស់នៅរបស់អ្នកក្នុងបន្ទុក ។

យោងទៅតាមគោលបំណង និងកត្តាចាំបាច់ដែលកម្មករកាត់ដេរបានសំណូមពរឡើង រូបមន្តសម្រាប់គណនាប្រាក់ឈ្នួលអប្បបរមាមួយដ៏ត្រឹមត្រូវ និង សមស្របទៅតាមស្ថានភាពឧស្សាហកម្មកាត់ដេរកម្ពុជា គឺ ប្រាក់ឈ្នួលអប្បបរមា = តម្រូវការចាំបាច់របស់កម្មករ + តម្រូវការចាំបាច់របស់អ្នកក្នុងបន្ទុក ។ តាមរយៈរូបមន្តនេះ យើងគណនាប្រាក់ឈ្នួលអប្បបរមាដែលមានកម្រិតផ្សេងៗគ្នា ដោយអាស្រ័យទៅលើសេណារីយ៉ូពីរយ៉ាង ។ សេណារីយ៉ូទី១ គឺគណនាប្រាក់ឈ្នួលអប្បបរមា ដោយផ្អែកទៅលើខ្ទង់ចំណាយបច្ចុប្បន្នសម្រាប់តម្រូវការចាំបាច់របស់កម្មករ តាមរយៈនេះយើងទទួលបានប្រាក់ឈ្នួលអប្បបរមាមានកម្រិត៧១,៩៩ដុល្លារក្នុង១ខែ ។ សេណារីយ៉ូទី២គឺ គណនាប្រាក់ឈ្នួលអប្បបរមា ដោយផ្អែកលើស្ថានភាពមួយដែលការចំណាយរបស់កម្មករលើអាហារមានកម្រិតស្មើនឹងការចំណាយរបស់មនុស្សទូទៅ (ពីកម្រិត១,0៦ដុល្លារក្នុង១ថ្ងៃ កើនទៅ ១,១៥ដុល្លារក្នុង១ថ្ងៃ, ផ្អែកតាមវិទ្យាស្ថានជាតិស្ថិតិ) ។ ពេលនោះ យើងទទួលបានប្រាក់ឈ្នួលអប្បបរមាមាន កម្រិត ៧៤,៨៥ដុល្លារក្នុង១ខែ ។

កម្មករបានបញ្ជាក់ថា ប្រាក់ឈ្នួលអប្បបរមាគួរតែពិនិត្យមើលឡើងវិញជារៀងរាល់ឆ្នាំ ដោយសារមូលហេតុ៣យ៉ាង ។ ទី១) សុខភាពរបស់កម្មករចុះខ្សោយជារៀងរាល់ឆ្នាំ ដែលធ្វើឱ្យចំណាយកើនទៅតាមនោះដែរ ។ ទី២) ស្ថានភាពសេដ្ឋកិច្ចពីមួយឆ្នាំទៅមួយឆ្នាំពិបាកនឹងស្មានទុក។ ទី៣) ស្ថានភាពគ្រួសារក៏ប្រែប្រួលពីមួយឆ្នាំទៅមួយឆ្នាំដែរ ដូចជា ត្រូវរៀបការ ឬ ត្រូវមានកូនជាដើម ។

ជាទូទៅ ការបង្កើតឱ្យមានប្រាក់ឈ្នួលអប្បបរមា វាអាចបង្កឱ្យមានផលវិបាកអវិជ្ជមានទៅដល់សេដ្ឋកិច្ច និង សង្គម ដែលដូច្នេះហើយ វាជារឿងចាំបាច់បំផុតដែលតម្រូវឱ្យមានការប្រៀបធៀបកម្រិតប្រាក់ឈ្នួលអប្បបរមាដែលរកឃើញជាមួយនឹងសូចនាករសំខាន់ៗដទៃទៀត :

- *ខ្សែបន្ទាត់ភាពក្រីក្រ :* ប្រាក់ឈ្នួលអប្បបរមាស្មើនឹង ៧១,៩៩ដុល្លារក្នុង១ខែ ឬ ២,៣២ដុល្លារក្នុង១ថ្ងៃ គឺស្ថិតនៅផ្នែកខាងលើផុតខ្សែបន្ទាត់ ដែលស្មើ0,៨១ដុល្លារនៅក្នុងទីក្រុងភ្នំពេញ 0,៦៨ដុល្លារនៅតាមជាយក្រុង និង 0,៦១ដុល្លារនៅជនបទ ។
- *ប្រាក់ឈ្នួលមធ្យម :* សូចនាករនេះជាទូទៅត្រូវបានប្រើសម្រាប់វាស់មើលភាពមិនស្មើគ្នានៃប្រាក់ឈ្នួលនៅក្នុងសេដ្ឋកិច្ច ។ តាមបទពិសោធន៍ ប្រាក់ឈ្នួលអប្បបរមាដ៏ត្រឹមត្រូវគឺមានកម្រិតស្មើនឹង ១១១% នៃGDPម្នាក់ៗ

(បើគិតជាថ្លៃទំនិញបច្ចុប្បន្ន) ឬ ១១៥% នៃ GDPម្នាក់ៗ (បើគិតជាតម្លៃថេរ) ។ ក៏ប៉ុន្តែ សូចនាករវាមិនសំខាន់សម្រាប់ករណីប្រទេសកម្ពុជាទេ ដោយសារមូលហេតុពីរយ៉ាង ។ ទី១ គោលបំណងដែលតម្រូវឱ្យមានប្រាក់ឈ្នួលអប្បបរមាគឺមិនមែនដើម្បីកាត់បន្ថយគម្លាតនៃប្រាក់ខែទេ ក៏ប៉ុន្តែ គឺដើម្បីធានាតម្រូវការចាំបាច់របស់កម្មករ និង អ្នកក្នុងបន្ទុក ព្រមទាំងការពារការធ្លាក់ចុះនៃប្រាក់ឈ្នួល ។ ទី២ GDPម្នាក់ៗ (៦៤,៣៧ ដុល្លារក្នុង១ខែ គិតជាថ្លៃទំនិញបច្ចុប្បន្ន) គឺមិនគ្រប់គ្រាន់ទេសម្រាប់តម្រូវការចាំបាច់របស់កម្មករ និង អ្នកក្នុងបន្ទុក (ដែលមាន ៧១,៩៩ដុល្លារក្នុង១ខែ) ។

- *តម្លៃបន្ថែមរបស់កម្មករម្នាក់ៗ :* តម្លៃបន្ថែមនៃកម្មករម្នាក់ៗ គឺជាលទ្ធផលការងារដែលកម្មករម្នាក់ៗផ្តល់ឱ្យរោងចក្រ ហើយវាគឺជាប្រភពនៃប្រាក់ឈ្នួលកម្មករ ។ ដូច្នេះ វាជារឿងសំខាន់បំផុតក្នុងការពិនិត្យមើលភាគរយនៃប្រាក់ឈ្នួលនៅក្នុងតម្លៃបន្ថែមនោះ ។ យើងឃើញថា គម្លាតរវាងប្រាក់ឈ្នួល និង តម្លៃបន្ថែមនៃកម្មករម្នាក់ៗមានកម្រិតធំ ហើយមាននិន្នាការកាន់តែធំទៀត ។ ក្នុងអំឡុងពេលពីឆ្នាំ ២០០៤ ដល់ ២០០៩ ប្រាក់ឈ្នួលជាក់ស្តែងរបស់កម្មករ មានជាមធ្យម២៤%នៃតម្លៃបន្ថែម; ក្នុងអំឡុងឆ្នាំ ២០០៧-២០០៩ វាបានធ្លាក់ចុះមកត្រឹម ១៩% ។ បើយើងធ្វើការប្រៀបធៀប ប្រទេសចិនមាន ៣៤% និង ប្រទេសឥណ្ឌូនេស៊ីមាន ២៥% ក្នុងឆ្នាំ ២០០៨ ។ មានន័យថា កម្មករនៅប្រទេសទាំងនោះទទួលចំណែកនៃផលការងារច្រើនជាងកម្មករនៅកម្ពុជា ។
- *កម្លាំងប្រកួតប្រជែង :* បើទោះជាប្រាក់ឈ្នួលអប្បបរមានៅក្នុងប្រទេសកម្ពុជាមានកម្រិតខ្ពស់ជាងប្រទេសដទៃ ទៀត (គិតជាPPP$) ក៏ដោយ ក៏ទំហំនៃការចំណេញនៅក្នុងឧស្សាហកម្មកាត់ដេរកម្ពុជា (៣១%) ខ្ពស់ជាងប្រទេសគូប្រកួតប្រជែងដែរ : ឥណ្ឌា (១១,៨%) ឥណ្ឌូនេស៊ី (10%) វៀតណាម (៦,៥%) ណេប៉ាល់ (៤,៤%) និង ប្រទេសចិន (៣,២% ដែលទាបជាងគេបំផុត) ។ ដូច្នេះ ការកើនឡើងនៃកម្រិតប្រាក់ឈ្នួលអប្បបរមា វានឹងមិនធ្វើឱ្យប្រទេសកម្ពុជាបាត់បង់កម្លាំងប្រកួតប្រជែង ឬក៏លែងជាប្រទេសគោលដៅអ្នកវិនិយោគទេ ។

## ***ផ្នែកទី ៤ : សេចក្តីសន្និដ្ឋាន និង អនុសាសន៍***

សម្រាប់ឧស្សាហកម្មកាត់ដេរកម្ពុជា ការសិក្សាស្រាវជ្រាវបានបង្ហាញថា :

- ប្រាក់ឈ្នួលអប្បបរមាបច្ចុប្បន្នដែលស្មើនឹង ៥0 ដុល្លារក្នុង១ខែ គឺមិនគ្រប់គ្រាន់សម្រាប់តម្រូវការចាំបាច់របស់កម្មករ និង អ្នកក្នុងបន្ទុកទេ ។ កម្មករត្រូវការតិចបំផុត ៧១,៩៩ ដុល្លារក្នុង១ខែ ក្នុងនោះ ៥៦,៩៩ ដុល្លារ បំពេញតម្រូវការចាំបាច់របស់កម្មករ និង ១៥ដុល្លារទៀតបំពេញតម្រូវការចាំបាច់របស់អ្នកក្នុងបន្ទុករបស់គេ ។ ជាពិសេស កម្មករបានស្នើសុំឱ្យមានប្រាក់គ្រប់គ្រាន់សម្រាប់ចំណាយលើអាហារ ដើម្បីរក្សាសុខភាព និង កម្លាំងក្នុង ការងារ ។

- ចាំបាច់ត្រូវពិនិត្យប្រាក់ឈ្នួលអប្បបរមាឡើងវិញជារៀងរាល់ឆ្នាំ ដើម្បីឆ្លើយតបទៅនឹងការផ្លាស់ប្តូរនៃស្ថានភាពសេដ្ឋកិច្ច (ដូចជា អតិផរណា) និង សុខភាពទ្រុតទ្រោមប្រចាំឆ្នាំ និងការប្រែប្រួលនៅក្នុងគ្រួសាររបស់កម្មករ ។
- នៅតំបន់ផ្សេងៗគ្នា វាមិនចាំបាច់តម្រូវការឱ្យមានប្រាក់ឈ្នួលអប្បបរមាខុសៗគ្នាទេ ពីព្រោះចំណាយសរុបសម្រាប់តម្រូវការចាំបាច់គឺស្មើគ្នាគ្រប់កន្លែង ។ ដូច្នេះ វាគួរតែមានប្រាក់ឈ្នួល អប្បបរមាតែមួយគត់ សម្រាប់ឧស្សាហកម្មកាត់ដេរទាំងមូល ។
- ក្នុងការតស៊ូមតិដើម្បីទាមទារប្រាក់ឈ្នួលអប្បបរមាត្រឹមត្រូវ វាគួរតែចាប់ផ្តើមពីកម្រិត៧១,៩៩ដុល្លារក្នុង១ខែសិន ពីព្រោះវាឆ្លុះបញ្ចាំងពីស្ថានភាពបច្ចុប្បន្នរបស់កម្មករ ។
- ការកើនឡើងនៃប្រាក់ឈ្នួលអប្បបរមានឹងមិនធ្វើឱ្យប្រទេសកម្ពុជាខាតបង់កម្លាំងប្រកួតប្រជែង ឬ លែងទាក់ទាញអ្នកវិនិយោគទេ ពីព្រោះទំហំចំណេញនៅក្នុងប្រទេសកម្ពុជា នៅខ្ពស់ជាងប្រទេសប្រកួតប្រជែង ដូចជា ឥណ្ឌូនេស៊ី វៀតណាម ណេប៉ាល់ និង ចិន ។ ផ្ទុយទៅវិញ ប្រាក់ឈ្នួលអប្បបរមា ដែលខ្ពស់នឹងធ្វើឱ្យផលិតភាពកាន់តែខ្ពស់ ពីព្រោះកម្មករម្នាក់ៗទទួលនូវអារម្មណ៍ធានាអំពីប្រាក់ចំណូល ។
- នៅក្នុងកិច្ចពិភាក្សាជាមួយក្រុមគោលដៅ កម្មករបានស្នើសុំឱ្យមានគណៈកម្មាធិការកំណត់ប្រាក់ឈ្នួលអប្បបរមាមួយ ដែលមានសមាជិកតំណាងឱ្យកម្មករ និង មន្ត្រីរដ្ឋាភិបាល ចូលរួមដោយស្របច្បាប់ក្នុងកិច្ចចរចា ។

# ផ្នែកទី ១ : សាវតារនៃគម្រោង

## ១. ប្រាក់ឈ្នួលអប្បបរមានៅប្រទេសកម្ពុជា

ក្នុងឆ្នាំ១៩៩៧ ច្បាប់ការងារត្រូវបានអនុម័តដោយរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ។ ច្បាប់នេះបានផ្តល់សិទ្ធិដល់ក្រសួងការងារ (MOL) ក្នុងការកំណត់កម្រិតប្រាក់ឈ្នួលអប្បបរមាសម្រាប់ការងារគ្រប់វិស័យទាំងអស់ ។ ក្រោយមកទៀត ក្នុងឆ្នាំដដែល ក្រសួងការងារបានចេញសេចក្តីប្រកាសព័ត៌មានស្តីពីប្រាក់ឈ្នួលអប្បបរមា ដោយបានកំណត់ប្រាក់ឈ្នួលអប្បបរមាស្មើនឹង ៤០ ដុល្លារក្នុង១ខែ ដែលជាលទ្ធផលនៃការចរចារវាងតំណាងនិយោជក និង និយោជិតក្នុងវិស័យវាយនភ័ណ្ឌ សម្លៀកបំពាក់ និងស្បែកជើង (ជារួម ឧស្សាហកម្មកាត់ដេរ)។ ក្នុងឆ្នាំ ២000 ប្រាក់ឈ្នួលអប្បបរមាត្រូវបានបង្កើនដល់ ៤៥ ដុល្លារក្នុង១ខែ ។ ៦ឆ្នាំក្រោយមក (ឆ្នាំ ២00៦) ក្រសួងការងារបានចេញសេចក្តីជូនដំណឹងមួយផ្សេងទៀត ដោយបានបង្កើនប្រាក់ឈ្នួលអប្បបរមា ដល់ ៥0 ដុល្លារក្នុង១ខែ សម្រាប់កម្មករក្នុងឧស្សាហកម្មកាត់ដេរ ដែលជាកម្រិតប្រាក់ឈ្នួលបច្ចុប្បន្ននៅក្នុងឧស្សាហកម្មនេះ ។

គណៈកម្មាធិការក្រុមប្រឹក្សាការងារ (LAC) ដែលមានតំណាងមកពីក្រសួងការងារ និយោជក និង សហជីព មានផែនការពិនិត្យឡើងវិញអំពីប្រាក់ឈ្នួលអប្បបរមានៅក្នុងវិស័យកាត់ដេរ ក្នុងឆ្នាំ២០១០ ដើម្បីសម្រេចថា តើត្រូវកម្រិតបច្ចុប្បន្ននេះត្រូវបង្កើន ឬក៏យ៉ាងណា ហើយបើសិនជាបង្កើន ត្រូវបង្កើនដល់កម្រិតណា ។

រហូតមកដល់ពេលបច្ចុប្បន្ន មិនមានប្រកាសស្តីពីប្រាក់ឈ្នួលអប្បបរមាសម្រាប់វិស័យផ្សេងៗ ហើយក៏មិនមានស្តង់ដារសម្រាប់ការកំណត់ប្រាក់ឈ្នួលអប្បបរមាឱ្យបានត្រឹមត្រូវដែរទេ ។ ក្រៅពីវិស័យកាត់ដេរ មិនមានប្រាក់ឈ្នួលអប្បបរមានៅក្នុងវិស័យដទៃទៀតទេ ។

## ២. គោលបំណងនៃការស្រាវជ្រាវ

គោលបំណងនៃការសិក្សាស្រាវជ្រាវនេះគឺ ដើម្បីបង្កើតបែបបទប្រកបដោយតម្លាភាព និង ភាពងាយស្រួលអនុវត្ត ក្នុងការកំណត់ប្រាក់ឈ្នួលអប្បបរមាសម្រាប់វិស័យកាត់ដេរកម្ពុជា ។ លទ្ធផលនៃការស្រាវជ្រាវ វានឹងផ្តល់ផលប្រយោជន៍ដល់ :

- ការរៀបរៀងបែបបទផ្លូវច្បាប់ ក្នុងពេលអនាគត អំពីប្រាក់ឈ្នួលអប្បបរមាសម្រាប់ដទៃទៀត និង ការរៀបចំប្រកាសអំពីការកំណត់ប្រាក់ឈ្នួលអប្បបរមា ។
- ការពិនិត្យប្រាក់ឈ្នួលអប្បបរមាឡើងវិញក្នុងឆ្នាំ២០១០ សម្រាប់ឧស្សាហកម្មកាត់ដេរ ដោយផ្តល់នូវទិន្នន័យថ្មីៗបំផុត និង ការវិភាគអំពីស្ថានភាពរបស់កម្មករកាត់ដេរ ។

នៅក្នុងបែបបទនៃការកំណត់ប្រាក់ឈ្នួលអប្បបរមា កិច្ចការសំខាន់របស់ការសិក្សាស្រាវជ្រាវនេះគឺ ស្វែងរកនូវគោលបំណង កត្តាចាំបាច់ និង រូបមន្ត សម្រាប់កំណត់ប្រាក់ឈ្នួលអប្បបរមា ព្រមទាំងកំណត់មូលដ្ឋាន និងអណត្តិនៃការពិនិត្យឡើងវិញ ។ លទ្ធផលនៃការសម្ភាសន៍ នឹងត្រូវយកមកប្រើក្នុងការគណនាប្រាក់ឈ្នួលអប្បបរមា ក្នុងឧស្សាហកម្មកាត់ដេរ ។

## ៣. ដំណើរការនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវចាប់ផ្តើមជាមួយនឹងការវិភាគលើ**ឯកសារសំខាន់ៗ**អំពីប្រព័ន្ធប្រាក់ឈ្នួលអប្បបរមា នៅក្នុងប្រទេសផ្សេងៗ ទាំងប្រទេសជឿនលឿន និង ប្រទេសកំពុងអភិវឌ្ឍន៍ ដើម្បីបង្កើតបែបបទរួមមួយ ។ ដើម្បីឱ្យមានសារៈសំខាន់ដល់ថ្នាក់ដឹកនាំគោលនយោបាយ និង ស្ថាប័នពាក់ព័ន្ធនៅប្រទេសកម្ពុជា ព្រមទាំងដើម្បីធានាថា ប្រាក់ឈ្នួលអប្បបរមាឆ្លុះបញ្ចាំងតម្រូវការជាក់ស្តែងរបស់កម្មករកាត់ដេរ ក្រុមការងារស្រាវជ្រាវបានកែសម្រួល វិធីសាស្ត្រនៃការស្រាវជ្រាវ និងវិភាគឱ្យសមស្របទៅនឹង**ស្ថានភាពជាក់ស្តែងរបស់កម្មករកាត់ដេរ ។** ក្នុងន័យនេះ ក្រុមស្រាវជ្រាវបាន**សម្ភាសន៍**កម្មករចំនួន ៣00 នាក់ នៅក្នុងតំបន់សំខាន់ៗចំនួន ៥ គឺ : ទីក្រុងភ្នំពេញ ខេត្តកំពង់ឆ្នាំង ខេត្តកណ្តាល ខេត្តព្រះសីហនុ និងខេត្តស្វាយរៀង (សូមមើលតារាងទី ១) ។ លើសពីនេះ ក្រុមស្រាវជ្រាវបានប្រមូលព័ត៌មានស៊ីជម្រៅតាមរយៈធ្វើការពិភាក្សាជាក្រុម (FGD) ជាមួយនឹងកម្មករចំនួន ៥0 នាក់នៅក្នុងតំបន់ទាំង៥នោះ ។

### តារាង ១ : ទំហំសំណាក

| តំបន់ | ចំនួន | ភាគរយ |
|---|---|---|
| ទីក្រុងភ្នំពេញ | ១៩៦ | ៦៥,៣ |
| ខេត្តកណ្ដាល* | ៣០ | ៩,៧ |
| ខេត្តព្រះសីហនុ | ២៤ | ៨,៣ |
| ខេត្តស្វាយរៀង | ២៥ | ៨,៣ |
| ខេត្តកំពង់ឆ្នាំង | ២៥ | ៨,៣ |
| **សរុប** | **៣០០** | **១០០,០** |

កំណត់សំគាល់ : ក្នុងចំណោមកម្មករដែលត្រូវបានសម្ភាសន៏នៅខេត្តកណ្ដាល មានបួននាក់ធ្វើការនៅទីក្រុងភ្នំពេញ ប៉ុន្តែធ្វើដំណើរពីផ្ទះទៅកន្លែងធ្វើការរៀងរាល់ថ្ងៃ

# ផ្នែកទី ២ : បែបបទសម្រាប់កំណត់ប្រាក់ឈ្នួលអប្បបរមា

## ៤. និយមន័យនៃប្រាក់ឈ្នួលអប្បបរមា

ដើម្បីឱ្យមានមូលដ្ឋានរួមក្នុងការចរចាប្រកបដោយប្រសិទ្ធភាព ដំបូងត្រូវដឹងនិយមន័យនៃពាក្យ "ប្រាក់ឈ្នួលអប្បបរមា" ជាមុនសិន ។ ពេលខ្លះ ពាក្យដូចជា "ចំណូលអប្បបរមា" និង "ប្រាក់ឈ្នួលសមរម្យ" ត្រូវបានប្រើច្រឡំជាមួយនឹងពាក្យ "ប្រាក់ឈ្នួលអប្បបរមា" បើទោះបីអត្ថន័យនៃពាក្យខាងលើនេះខុសគ្នាក៏ដោយ ។ *និយមន័យត្រូវមានដូចខាងក្រោមនេះ :*

- ***ប្រាក់ឈ្នួលអប្បបរមា*** ជាប្រាក់ឈ្នួលមួយដែលនិយោជកមិនអាចបន្ទាបកម្រិតវាបាន ហើយ "កម្រិតរបស់វាត្រូវបានកំណត់ និង ធានាដោយច្បាប់ ។"[1]
- ***ចំណូលអប្បបរមា*** ជាកម្រិតចំណូលមួយដែលធានាឱ្យពលរដ្ឋម្នាក់ និងគ្រួសាររបស់គេរស់បាននៅក្នុងសង្គម ដោយមិនអាស្រ័យទៅលើប្រភេទការងាររបស់គេទេ ។ នៅក្នុងប្រទេសដែលមានប្រព័ន្ធប្រាក់ចំណូលអប្បបរមា ប្រសិនបើចំណូលពីការងារតិចជាងចំណូលអប្បបរមា រដ្ឋាភិបាលត្រូវផ្តល់ឱ្យកម្មករនូវចំនួនប្រាក់ដែលខ្វះ ។[2]
- ***ប្រាក់ឈ្នួលសមរម្យ*** ជាប្រាក់ឈ្នួលមួយដែលមានកម្រិតគ្រប់គ្រាន់ សម្រាប់តម្រូវការចាំបាច់របស់កម្មករ និង គ្រួសារ ព្រមទាំងមានសល់សម្រាប់សន្សំដើម្បីអនាគត ។[3]

តាមរយៈនិយមន័យនេះ ប្រាក់ឈ្នួលអប្បបរមាជាទូទៅតិចជាង ឬ ស្មើប្រាក់ចំណូលអប្បបរមា និង ប្រាក់ឈ្នួលសមរម្យ ។ ការសិក្សាស្រាវជ្រាវនេះផ្តោតទៅលើប្រាក់ឈ្នួលអប្បបរមាតែប៉ុណ្ណោះ ។

## ៥. និន្នាការនៃប្រាក់ឈ្នួលអប្បបរមាក្នុងសកលលោក

ប្រាក់ឈ្នួលអប្បបរមាជាឧបករណ៍គោលនយោបាយទូទៅ ដែលត្រូវបានប្រើប្រាស់ដោយបណ្តាប្រទេសស្ទើរតែទាំងអស់ ។ ក្នុងអំឡុងពេលពីឆ្នាំ ២០០១ ដល់ ២០០៧ **ប្រាក់ឈ្នួលអប្បបរមាពិតបានកើនឡើងគួរឱ្យកត់សំគាល់** ទាំងនៅប្រទេសកំពុងអភិវឌ្ឍន៍ និង នៅប្រទេសជឿនលឿន ដើម្បីកាត់បន្ថយគម្លាតនៃក្នុងប្រាក់ចំណូល និង ដើម្បីកាត់បន្ថយភាពក្រីក្រ

[1] See Wikipedia, "minimum income", and (Pember, R. & Dupré, M., Unknowm)
[2] (Pember, R. & Dupré, M., Unknown)
[3] (Prasanna, R. and Gowthaman, B., 2005)

របស់កម្មករ ។ ជាមធ្យម ប្រាក់ឈ្នួលអប្បបរមាពិតបានកើនឡើង ៥,៧% ក្នុង១ឆ្នាំ (៣,៨%នៅប្រទេសជឿន លឿន និង ៦,៥%នៅប្រទេសកំពុងអភិវឌ្ឍន៍) ។[4]

និន្នាការកើនឡើងក្នុងប្រាក់ឈ្នួលអប្បបរមានៅលើពិភពលោក បានកើតមានឡើងក្នុងពេលដែលប្រទេសជាច្រើនសម្រេចបាននូវកំណើនសេដ្ឋកិច្ចប្រកបដោយនិរន្តរភាព ។ ការកែតម្រូវប្រាក់ឈ្នួលអប្បបរមាអាចនឹងមានការលំបាកជាងមុនក្នុងស្ថានភាពសេដ្ឋកិច្ចបច្ចុប្បន្ន ដែលកំពុងជួបប្រទះវិបត្តិ ។ ការធ្លាក់ចុះនៃសេដ្ឋកិច្ចបានជំរុញឱ្យមានការផ្តោតអារម្មណ៍ទៅលើកត្តាចំណាយលើប្រាក់ឈ្នួលរបស់កម្មករ ដែលធ្វើឱ្យមានការបារម្ភកាន់តែខ្លាំងឡើងអំពីការបាត់បង់ការងារ ។ ក៏ប៉ុន្តែ ប្រាក់ឈ្នួលអប្បបរមាក៏មានសារសំខាន់សម្រាប់ស្តារស្ថានភាពសេដ្ឋកិច្ចឱ្យងើបឡើងវិញផងដែរ ពីព្រោះ វាមានតួនាទីធានាឱ្យកម្មករមានប្រភពសម្រាប់ចំណាយលើតម្រូវការចាំបាច់ជារហូត ។[5]

ប្រទេសមួយចំនួនបានសម្រេចចិត្តមិនបណ្តោយឱ្យវិបត្តិសេដ្ឋកិច្ចពិភពលោកនេះ បង្អាក់ដំណើរការអនុវត្តន៍គោលនយោបាយប្រាក់ឈ្នួលអប្បបរមារបស់គេទេ ដូចជា នៅប្រទេសអេស្ប៉ាញ និង ប្រទេសប្រេស៊ីល ប្រាក់ឈ្នួលអប្បបរមាពិតត្រូវបានតម្លើង ដើម្បីសម្រេចបាននូវគោលដៅសេដ្ឋកិច្ច និងសង្គមកិច្ច រយៈពេលវែង ។ នៅប្រទេសអាល្លឺម៉ង់ រដ្ឋាភិបាលបានសម្រេចពង្រីកវិសាលភាព នៃប្រាក់ឈ្នួលអប្បបរមាដែលត្រូវបានចរចាដោយសមូហភាព ទៅដល់វិស័យផ្សេងៗទៀត ដែលបានស្រូបយកកម្មករចូលធ្វើការសរុបចំនួន ១,៧ លាននាក់ ។ ផ្ទុយពីនេះ ប្រទេសមួយចំនួនបានសម្រេចចិត្តបំបាត់ប្រាក់ឈ្នួលអប្បបរមា ដូចជា នៅប្រទេសកូរ៉េខាងត្បូង ។[6]

សម្រាប់ឧស្សាហកម្មកាត់ដេរជាសកល បណ្តាប្រទេសធំៗដែលនាំចេញនូវសម្លៀកបំពាក់ បានអនុវត្តន៍ប្រព័ន្ធប្រាក់ឈ្នួលអប្បបរមា សម្រាប់កម្មករវាយនភ័ណ្ឌ និង កាត់ដេរ ។ រូបភាពទី១ខាងក្រោមបង្ហាញពីកម្រិតប្រាក់ឈ្នួលអប្បបរមានៅបណ្តាប្រទេសនាំសម្លៀកបំពាក់ចេញនានា ដែលជាគូប្រកួតប្រជែងជាមួយនឹងប្រទេសកម្ពុជា ។ ប្រាក់ឈ្នួលអប្បបរមាត្រូវបានគណនាជាតម្លៃដុល្លារនៅក្នុងប្រទេសអាមេរិក (PPP$) ដើម្បីធ្វើការប្រៀបធៀប រវាងប្រទេសទាំងនោះ ។ PPP$ គឺជាអត្រាប្តូរប្រាក់មួយដែលកើតឡើងពីការប្រៀបធៀបគ្នារវាងតម្លៃនៃទំនិញនៅក្នុងប្រទេសណាមួយ ជាមួយនឹងតម្លៃនៃទំនិញដូចគ្នានៅក្នុងប្រទេសអាមេរិក ។ កត្តាចម្បងដែលមានឥទ្ធិពលទៅលើកម្រិតនៃ PPP$ គឺការវិវឌ្ឍន៍នៃអតិផរណានៅក្នុងប្រទេសអាមេរិក និង ប្រទេសណាមួយផ្សេងទៀតដែលយកមកប្រៀបធៀប ។ ប្រសិនជាអតិផរណានៅប្រទេស

[4] (ILO, 2008)
[5] Paraphrased from (ILO, 2009)
[6] (ILO, 2009)

នោះ ខ្ពស់ជាងនៅប្រទេសអាមេរិក នោះ PPP$ នឹងមានកម្រិតទាប ។ តែប្រសិនជាអតិផរណានៅប្រទេសនោះទាបជាងនៅប្រទេសអាមេរិក នោះ PPP$ នឹងមានកម្រិតខ្ពស់ ។

ដូចមាននៅក្នុងរូបភាពទី១ ប្រាក់ឈ្នួលអប្បបរមាខ្ពស់បំផុតគឺនៅតៃវ៉ាន់ (៩៥៥ PPP$) ហើយទាបជាងគេបំផុតនៅប្រទេស បង់ក្លាដេស (៦៩ PPP$) ។ កម្រិតប្រាក់ឈ្នួលអប្បបរមានៅប្រទេសកម្ពុជាគឺ ១៥៦ PPP$ (ដោយប្រាក់ឈ្នួលអប្បបរមាគិតជាថ្លៃដុល្លារបច្ចុប្បន្ននៅកម្ពុជា ស្មើនឹង៥0ដុល្លារក្នុង១ខែ និង អតិផរណាមាន៥,៩%[7] ក្នុងឆ្នាំ ២00៧) ទាបជាងនៅប្រទេសចិន (២0៤ PPP$) ប៉ុន្តែប្រហាក់ប្រហែលគ្នានឹងនៅប្រទេសឥណ្ឌូនេស៊ី (១៤២ PPP$) និង នៅប្រទេសវៀតណាម (១២0 PPP$) ។

**រូបភាពទី ១ : ប្រាក់ឈ្នួលអប្បបរមានៅបណ្តាប្រទេសនាំសម្លៀកបំពាក់ចេញសំខាន់ៗ (គិតជា PPP$ , ២00៧)**




ប្រភព : អង្គការពលកម្មអន្តរជាតិ (២00៩)

[7] National Institute of Statistics

## ៦. ដំណាក់កាលនៃការវិភាគ

ដើម្បីឱ្យដំណោះស្រាយមានប្រសិទ្ធភាព និង ឆ្លើយតបទៅនឹងស្ថានភាពនៃក្រុមគោលដៅ ដោយកាត់បន្ថយឥទ្ធិពលអវិជ្ជមានដល់ក្រុមដទៃទៀតក្នុងសង្គម ការវិភាគត្រូវតែផ្អែកទៅមូលដ្ឋានជាក់ស្តែងដោយខានមិនបាន ។ នៅពេលដែលនយោបាយនៃប្រាក់ឈ្នួលអប្បបរមាត្រូវបានតាក់តែង វាមាន៣ដំណាក់កាលសំខាន់បំផុតដែលយកមកប្រើ :

1) កំណត់**គោលបំណង**នៃគោលនយោបាយ : តើយើងចង់ឱ្យប្រាក់ឈ្នួលអប្បបរមាសម្រេចបានអ្វី? ឬ ហេតុអ្វីបានជាចាំបាច់ត្រូវមានប្រាក់ឈ្នួលអប្បបរមា?
2) កំណត់**កត្តាចាំបាច់** : នៅពេលដែលកំណត់គោលបំណងនៃប្រាក់ឈ្នួលអប្បបរមាច្បាស់លាស់ហើយ យើងចាំបាច់ត្រូវកំណត់កត្តាចាំបាច់ទាំងឡាយ ឬស្តង់ដារសម្រាប់វិនិច្ឆ័យថាតើ ប្រាក់ឈ្នួលអប្បបរមានឹងសម្រេចបានគោលបំណងនោះដែរឬទេ ។ តើកត្តាអ្វីខ្លះចាំបាច់ត្រូវតែដាក់បញ្ចូលទៅក្នុងការគណនាប្រាក់ឈ្នួលអប្បបរមានោះ?
3) បង្កើត**រូបមន្ត**គណនាប្រាក់ឈ្នួលអប្បបរមា : ក្រោយពីឆ្លងកាត់ដំណាក់កាលទី១ និង ទី២ យើងមានមូលដ្ឋានរៀបរៀងសមីការ សម្រាប់គណនាប្រាក់ឈ្នួលអប្បបរមាដ៏ត្រឹមត្រូវមួយ ។

ដំណាក់កាលនៃការវិភាគទាំងនេះ (បង្ហាញក្នុងរូបភាពទី២) វាជាក្របខ័ណ្ឌក្នុងការកំណត់ប្រាក់ឈ្នួលអប្បបរមា ។ នៅក្នុងផ្នែកបន្ទាប់ៗទៀត យើងនឹងបង្ហាញទិដ្ឋភាពទូទៅអំពី គោលបំណង កត្តាចាំបាច់ផ្សេងៗ និង រូបមន្តនៃការកំណត់ប្រាក់ឈ្នួលអប្បបរមា ដែលធ្លាប់បានអនុវត្តន៍នៅក្នុងប្រទេសដទៃទៀត។ ផ្នែកទី៣នៃរបាយការណ៍នេះនឹងធ្វើការកែសម្រួលបែបផែននៃការគណនាឱ្យស្របទៅតាមស្ថានភាពនៃឧស្សាហកម្មកាត់ដេរក្នុងប្រទេសកម្ពុជា និងជាពិសេសទៅតាមតម្រូវការនៃកម្មករ ដោយប្រើប្រាស់នូវព័ត៌មានដែលទទួលពីការសម្ភាសន៍ និង ព័ត៌មានស៊ីជម្រៅដែលបានតាមរយៈពិភាក្សាជាក្រុម ។

**រូបភាពទី ២ : ជំហ៊ានៃនការវិភាគនៃការស្រាវជ្រាវ**




## ៧. គោលបំណងនៃប្រាក់ឈ្នួលអប្បបរមា

នៅក្នុងផ្នែកនេះ យើងនឹងបង្ហាញដោយសង្ខេបអំពីគំហើញពីការស្រាវជ្រាវឯកសារ ទាក់ទងនឹងការអនុវត្តន៍គោលនយោបាយប្រាក់ឈ្នួលអប្បបរមា នៅប្រទេសផ្សេងៗទៀត ។ តាមរយៈនេះ យើងនឹងអាចរៀបចំបែបបទរួមមួយ សម្រាប់កំណត់ប្រាក់ឈ្នួលអប្បបរមាឱ្យបានត្រឹមត្រូវ ។

ហេតុអ្វីបានជាចាំបាច់ត្រូវមានប្រាក់ឈ្នួលអប្បបរមា? ប្រាក់ឈ្នួលអាចមានទម្ងន់យ៉ាងខ្លាំងទៅលើការប្រឹងប្រែង ក្នុងការកាត់បន្ថយភាពក្រីក្រ លើកកម្ពស់ជីវភាពរស់នៅ និង បង្កើនផលិតភាពការងារ ។ ជាទូទៅ គោលបំណងនៃនយោបាយប្រាក់ឈ្នួលអប្បបរមាមាន៤សម្រាប់ : ធានាតម្រូវការចាំបាច់ក្នុងជីវភាពរស់នៅ, ការពារការធ្លាក់ចុះនៃប្រាក់ឈ្នួល, លើកទឹកចិត្តឱ្យកម្មករប្រឹងធ្វើការ និងធ្វើឱ្យមានសមភាពប្រាក់ចំណូល ។ គោលបំណងនៃនយោបាយប្រាក់ឈ្នួលអប្បបរមាតែងតែខុសគ្នាពីប្រទេសមួយទៅប្រទេសមួយ អាស្រ័យទៅតាមបរិបទសេដ្ឋកិច្ច សង្គមកិច្ច និង ដំណាក់កាលនៃការអភិវឌ្ឍន៍ ។ យើងនឹងបង្ហាញដោយសង្ខេបអំពីគោលបំណងនីមួយៗ ដូចតទៅ :

## ធានាតម្រូវការចាំបាច់របស់កម្មករ

ក្នុងប្រវត្តិសាស្ត្រ ប្រាក់ឈ្នួលអប្បបរមាត្រូវបានបង្កើតឡើងក្នុងគោលបំណងដើម្បីឱ្យ កម្មករទទួលប្រាក់ឈ្នួលក្នុងកម្រិតមួយដែលយ៉ាងអន់ណាស់ក៏អាចធានាជីវិតរស់នៅ ។ ក្នុងន័យនេះគោលបំណងសំខាន់បំផុត គឺ ការធានាលើចំណាយនៃតម្រូវការចាំបាច់ (អាហារ សម្លៀកបំពាក់ ការស្នាក់នៅ សុខភាព និង ការសិក្សា) ព្រមទាំងពេលខ្លះសម្រាប់បំពេញតម្រូវការរបស់អ្នកក្នុងបន្ទុកផងដែរ ។

## ការពារការធ្លាក់ចុះនៃប្រាក់ឈ្នួល

គោលបំណងមួយផ្សេងទៀតសម្រាប់ការបង្កើតប្រាក់ឈ្នួលអប្បបរមាគឺ ដើម្បីផ្តល់នូវសុវត្ថិភាពចំណូលដល់កម្មករដែលងាយរងគ្រោះ ជាពិសេសកម្មករដែលធ្វើការនៅក្នុងវិស័យសេដ្ឋកិច្ចដែលងាយនឹងប្រែប្រួលខ្លាំង។ លើសពីនេះទៀតសហគ្រាសដែលមានការប្រកួតប្រជែងខ្លាំង ច្រើនតែកាត់បន្ថយចំណាយផលិតកម្ម តាមរយៈបន្ទាបប្រាក់ឈ្នួលរបស់កម្មករ ។ ដូច្នេះ គោលបំណងនៃការបង្កើតឱ្យមានប្រាក់ឈ្នួលអប្បបរមាគឺ ដើម្បីការពារមិនឱ្យមានការធ្លាក់ចុះជ្រុលនៃប្រាក់ឈ្នួលរបស់កម្មករនៅក្នុងវិស័យរបៀបខាងលើ ។

## លើកទឹកចិត្តកម្មករឱ្យប្រឹងធ្វើការ

នៅក្នុងប្រទេសមួយចំនួន ដូចជា នូវែលហ្សេឡង់[8] ប្រាក់ឈ្នួលអប្បបរមាត្រូវបានបង្កើតឡើង ដើម្បីលើកទឹកចិត្តមនុស្សឱ្យធ្វើការ ។ គោលបំណងនៃប្រាក់ឈ្នួលអប្បបរមាក្នុងន័យ គឺដើម្បីទាក់ទាញប្រជាជនឱ្យធ្វើការ ពីព្រោះការខាតនៃឱកាសវាកើតមានឡើង បើសិនជាគេមិនធ្វើការវិញ ។ គោលបំណងរបៀបនេះមិនសូវសំខាន់គេសម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍ ជាពិសេសប្រទេសទាំងឡាយណាដែលនៅមិនទាន់មានប្រព័ន្ធសុវត្ថភាពសម្រាប់និកម្មជន ។ ប្រជាជនជាច្រើននៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍មិនអាចរស់បាន ដោយមិនមានរកចំណូលនោះទេ ។

## កាត់បន្ថយគម្លាតនៃការបែងចែកផលកំណើនសេដ្ឋកិច្ច

គោលបំណងទី៤សម្រាប់ការកំណត់ប្រាក់ឈ្នួលអប្បបរមា គឺដើម្បីធានាថា កម្មករនឹងទទួលបាននូវចំណែកត្រឹមត្រូវមួយពីកំណើនសេដ្ឋកិច្ច ។ គោលបំណងចម្បងគឺ ធានាថាកម្មករមិនត្រូវបានកេងប្រវ័ញ្ច ផ្ទុយទៅវិញត្រូវតែទទួលបាននូវការលើកទឹកចិត្តសម្រាប់ការងាររបស់គេ ។ ប្រាក់ឈ្នួលអប្បបរមាដែលគិតបញ្ចូលទាំងរង្វាន់សម្រាប់ជោគជ័យរបស់រោងចក្រ

[8] (New Zealand Employers' Federation, 1999)

គឺជាមធ្យោបាយមួយសម្រាប់លើកទឹកចិត្តដល់កម្មករ ក្នុងការបង្កើនផលិតភាពនៃការងាររបស់ខ្លួនថែមទៀត ។ ជាមួយគ្នានេះដែរ គោលបំណងនេះគឺដើម្បីកាត់បន្ថយគម្លាតនៃប្រាក់ចំណូលនៅក្នុងសេដ្ឋកិច្ច ។

## ៨. កត្តាចាំបាច់ដែលត្រូវដាក់បញ្ចូលក្នុងការគណនាប្រាក់ឈ្នួលអប្បបរមា

វគ្គនេះបង្ហាញអំពីកត្តាចាំបាច់ទូទៅ ដែលគេយកមកដាក់បញ្ចូលទៅក្នុងគណនាប្រាក់ឈ្នួលអប្បបរមាទូទាំងពិភពលោក ដូចជា តម្រូវការចាំបាច់របស់កម្មករ កម្រិតទូទៅនៃប្រាក់ឈ្នួល ប្រព័ន្ធសន្តិសុខសង្គម និង កត្តាសេដ្ឋកិច្ច ។

### តម្រូវការចាំបាច់របស់កម្មករ

កត្តាសំខាន់បំផុតដែលគិតបញ្ចូលនៅក្នុងប្រាក់ឈ្នួលអប្បបរមាគឺ តម្រូវការចាំបាច់របស់កម្មករ ។ ជាគោលការណ៍ ប្រាក់ឈ្នួលអប្បបរមាមិនត្រូវនៅក្រោមកម្រិតនៃចំណាយសម្រាប់តែមួយរស់ទេ ។ ប្រាក់ឈ្នួលអប្បបរមាត្រូវតែមានកម្រិតមួយដែលកម្មករអាចដោះស្រាយតម្រូវការចាំបាច់របស់គេ ដូចជា អាហារ សម្លៀកបំពាក់ ការស្នាក់នៅ និង សុខភាពជាដើម ។ យើងអាចដឹងតម្រូវការចាំបាច់តាមរយៈការពិនិត្យទៅលើខ្ទង់ចំណាយរបស់កម្មករ ។ ផ្ទុយទៅវិញ វាមិនត្រូវផ្អែកទៅលើអ្វីដែលកម្មករចង់បាន ឬក៏ស្រមើស្រមៃទេ ពីព្រោះបើមិនដូច្នោះទេ ការទាមទារនឹងមិនមានសារៈសំខាន់ ហើយក៏អាចពង្រីកគម្លាតនៃប្រាក់ចំណូលនៅក្នុងសង្គម ។[9]

### កម្រិតទូទៅនៃប្រាក់ឈ្នួល

កម្រិតទូទៅនៃប្រាក់ឈ្នួលត្រូវបានគឺជាប្រាក់ចំណូលមធ្យមរបស់ប្រជាជនម្នាក់ៗ ។ ជាធម្មតា ប្រភាគរវាងប្រាក់ឈ្នួលអប្បបរមាជាមួយនឹងប្រាក់ចំណូលមធ្យម គឺជាខ្នាតមួយដ៏សំខាន់សម្រាប់ប្រៀបធៀបស្ថានភាព នៃកម្មករជាមួយនឹងប្រជាជនទូទៅ ។

នៅក្នុងប្រទេសជាច្រើន ប្រាក់ឈ្នួលអប្បបរមាត្រូវបានកំណត់ក្នុងចន្លោះពី ៣០% ទៅ ៦០% នៃប្រាក់ចំណូលប្រជាជនម្នាក់ៗ ។ ប៉ុន្តែនៅប្រទេសកំពុងអភិវឌ្ឍន៍ វានៅចន្លោះពី ៣០% ទៅលើសពី ១០០% ។

[9] (Shaheed, Z. Notes on Minimum Wage Fixing, p.113)

### ប្រព័ន្ធសន្តិសុខសង្គម

ប្រព័ន្ធសន្តិសុខសង្គមមានតួនាទីជាសំណាញ់សុវត្ថិភាពសម្រាប់ប្រជាជនងាយរងគ្រោះ មានន័យថាវាគឺជាសញ្ញានៃតម្រូវការឱ្យមានប្រាក់ឈ្នួលអប្បបរមាមួយដែលមានកម្រិតសមរម្យ ។ នៅក្នុងប្រទេសមួយចំនួន គោលបំណងធំបំផុតនៃការបង្កើតឱ្យមានប្រាក់ឈ្នួល អប្បបរមាគឺ ដើម្បីធ្វើជាសំណាញ់សុវត្ថិភាពសម្រាប់កម្មករ ។[10]

### កត្តាសេដ្ឋកិច្ច

កត្តាសេដ្ឋកិច្ចក៏ជាកត្តាចាំបាច់ដ៏សំខាន់មួយផងដែរ ក្នុងការពិចារណានៅពេលកំណត់ប្រាក់ឈ្នួលអប្បបរមា ដើម្បីបញ្ចៀសការខ្វែងគំនិតគ្នារវាងភាគីពាក់ព័ន្ធ (ដូចជាកម្មករ និយោជក និង រដ្ឋាភិបាល) និងការបះបោរប្រឆាំងដោយយថាហេតុ ។ កត្តាសេដ្ឋកិច្ចសំខាន់ៗរួមមាន អត្រានៃភាពមានការងារធ្វើ, អត្រានៃភាពគ្មានការងារធ្វើ, ឥទ្ធិពលរបស់ប្រាក់ឈ្នួលអប្បបរមាដែលអាចមានទៅលើស្ថានភាពនៃភាពគ្មានការងារធ្វើ, ផលិតភាពការងារ និង កម្លាំងប្រកួតប្រជែង ។ កត្តាចាំបាច់ពីរផ្សេងទៀតគឺ សមត្ថភាពបង់ប្រាក់ឈ្នួលរបស់និយោជក និងល័ក្ខខ័ណ្ឌសម្រាប់អភិវឌ្ឍន៍សេដ្ឋកិច្ច ។[11]

## ៩. រូបមន្តគណនាប្រាក់ឈ្នួលអប្បបរមា

តើប្រាក់ឈ្នួលអប្បបរមាត្រូវបានកំណត់ដោយរបៀបណា? បើទោះបីជាប្រាក់ឈ្នួលអប្បបរមាគឺជាឧបករណ៍ទូទៅសម្រាប់នយោបាយកាត់បន្ថយភាពក្រីក្រក៏ដោយ ក៏មកដល់ពេលនេះនៅមិនទាន់មានស្តង់ដាររួមមួយសម្រាប់គណនាកម្រិតរបស់វាឱ្យបានត្រឹមត្រូវនៅឡើយទេ ។ ប៉ុន្តែ ជាគោលលការណ៍ រូបមន្តសម្រាប់គណនាត្រូវគិតអំពីគោលបំណង និង កត្តាចាំបាច់ដែលតម្រូវឱ្យមានប្រាក់ឈ្នួលអប្បបរមា ។ ប្រាក់ឈ្នួលអប្បបរមាត្រឹមត្រូវគឺជាផលបូកនៃកត្តាចាំបាច់ដែលប្រែប្រួលទៅចំនួនគោលបំណងដែលមាន (សូមមើលរូបភាពទី៣) ។

#### រូបភាពទី ៣ : រូបមន្តទូទៅសម្រាប់ការគណនាប្រាក់ឈ្នួលអប្បបរមា

$$\text{ប្រាក់ឈ្នួលអប្បបរមា} = \sum_{\text{គោលបំណងទី១}}^{\text{គោលបំណងទី}} \text{កត្តាចាំបាច់}$$

[10] (Shaheed, Z. Notes on Minimum Wage Fixing, p. 114)
[11] (Shaheed, Z. Notes on Minimum Wage Fixing, p. 113)

# ផ្នែកទី ៣ : លទ្ធផលនៃការស្រាវជ្រាវ

## ១០. អំពីកម្មករ

មុនពេលចាប់ផ្តើមការវិភាគ ចាំបាច់បំផុតត្រូវយល់ដឹងពីស្ថានភាពរបស់ក្រុមគោលដៅ នៃប្រាក់ឈ្នួលអប្បបរមា-កម្មករកាត់ដេរ ។ ការយល់ដឹងនេះនឹងជាមូលដ្ឋាននៃការវិភាគ ជាពិសេសអំពីគោលបំណង តម្រូវឱ្យមានប្រាក់ឈ្នួលអប្បបរមា និង កត្តាចាំបាច់ទាំងឡាយដែលត្រូវដាក់បញ្ចូលទៅក្នុងការគណនា ។

### ១០.១ សាវតារ

ក្នុងចំណោមកម្មករ៣០០នាក់ដែលត្រូវបានសម្ភាសន៍ មាន៩០% (២៧០នាក់) ជាស្ត្រី ។ ជាមធ្យម កម្មករមានអាយុ ២៤ ឆ្នាំ នៅពេលដែលភាគច្រើនគេមានអាយុ២១ឆ្នាំ ។ ៦៨% នៃកម្មករ៣០០នាក់គឺនៅលីវ, ២៥% រៀបការ និង ៧% ជាមេម៉ាយ/ពោះម៉ាយ ។ មានតែ១២% (ឬ៣៥នាក់) ប៉ុណ្ណោះ ជាមេគ្រួសារ ក្រៅពីនេះ (៨៨% ឬ ២៦៥នាក់) ជាអ្នករកចំណូល ផ្គត់ផ្គង់គ្រួសារ ។ កម្មករស្ទើរតែទាំងអស់ (៩៤,៣%) នៃកម្មករគឺមិនមានកម្រិតវប្បធម៌លើសពីថ្នាក់ទី៩ឡើយ (សូមមើលតារាងទី២) ។

តារាងទី ២ : កម្រិតវប្បធម៌របស់អ្នកត្រូវបានសម្ភាសន៍

| កម្រិតវប្បធម៌ដែលសម្រេចបាន | ចំនួន | ភាគរយ | ភាគរយបូកបន្ត |
|---|---|---|---|
| មិនចេះអក្សរសោះ ឬស្ទើរតែមិនចេះអក្សរសោះ | ១១ | ៣,៧ | ៣,៧ |
| មិនចប់បឋមសិក្សា | ៧៧ | ២៥,៧ | ២៩,៣ |
| បឋមសិក្សា (ថ្នាក់ទី១-៦) | ៧១ | ២៣,៧ | ៥៣,០ |
| អនុវិទ្យាល័យ (ថ្នាក់ទី ៧-៩) | ១២៤ | ៤១,៣ | ៩៤,៣ |
| វិទ្យាល័យ (ថ្នាក់ទី១០-១២) | ១៥ | ៥,០ | ៩៩,៣ |
| សញ្ញាប័ត្របណ្តុះបណ្តាលបច្ចេកទេស (១-៣ឆ្នាំ) | ១ | ០,៣ | ៩៩,៧ |
| បរិញ្ញាប័ត្ររង ឬខ្ពស់ជាង | ១ | ០,៣ | ១០០,០ |
| **សរុប** | **៣០០** | **១០០,០** | |

កម្មករដែលត្រូវបានសម្ភាសន៍នៅក្នុងទីក្រុងភ្នំពេញ ៩០% មកពីខេត្ត ជាពិសេសមកពីព្រៃវែង (២៣%) និង ខេត្តកំពង់ចាម (២០%) ក្រៅពីនេះមកពីខេត្តផ្សេងៗទៀត ដូចជា ខេត្តស្វាយរៀង ខេត្តកំពង់ធំ ខេត្តកណ្តាល និង ខេត្តតាកែវ ។ កម្មករ ៦៧% ធ្វើការនៅក្នុងខេត្តកណ្តាល គឺជាកម្មករចំណាកស្រុក ជាពិសេសមកពីខេត្តព្រៃវែង នៅពេលដែល ៣៣% ផ្សេងទៀតគឺជាកម្មករមូលដ្ឋាន ។ ស្រដៀងគ្នានេះដែរ កម្មករ ៦៧% ធ្វើការនៅក្នុងខេត្តព្រះសីហនុ ក៏ជាកម្មករចំណាកស្រុកផងដែរ ជាពិសេសមកពីខេត្តកំពត ។ ចំណែកឯ កម្មករទាំងអស់ដែលធ្វើការនៅខេត្តស្វាយរៀង និង ខេត្តកំពង់ឆ្នាំង គឺជាប្រជាជនក្នុងខេត្ត ។

## ១០.២ ស្ថានភាពគ្រួសារ

កម្មករជាទូទៅមានសមាជិក៤នាក់នៅក្នុងគ្រួសារ (រួមទាំងអ្នកត្រូវបានសម្ភាសន៍ ដូចបង្ហាញក្នុងរូបភាពទី៤) ដែលក្នុងនោះ ២នាក់ជាអ្នករកចំណូល ម្នាក់ជាកសិករ និង ម្នាក់ទៀតជាកម្មករនៅរោងចក្រ ។ ដោយមិនរាប់បញ្ចូលចំណូលរបស់កម្មករ គ្រួសារនីមួយៗរកចំណូលបានជាមធ្យមប្រហែល ៦៦ដុល្លារក្នុង១ខែ ។ បើគិតជាភាគច្រើន គ្រួសារចំនួន៦០% រកចំណូលបានមិនលើសពី៥០ដុល្លារក្នុង១ខែទេ ។ ៥៤%នៃ៣០០គ្រួសារមានដីតូចជាង ១ ហិចតា ។ ជាទូទៅ កម្មករស្ទើរតែទាំងអស់មកពីគ្រួសារក្រីក្រ ហើយដោយសារតែវប្បធម៌សងគុណគ្រួសារដ៏ខ្លាំង កម្មករមានកាតព្វកិច្ចត្រូវជួយជាលុយកាក់ ដើម្បីទំនុកបម្រុងទៅដល់សមាជិកគ្រួសារដទៃទៀត ។

## រូបភាពទី ៤ : ទំហំគ្រួសារ




កំណត់សំគាល់ : 1 មានន័យថា អ្នកត្រូវបានសម្ភាសន៍មិនមានអ្នកក្នុងបន្ទុក

## ១០.៣ ស្ថានភាពការងារ

កម្មករចំនួនទាំង៣០០នាក់គឺមកពីរោងចក្រចំនួន៧៤ ។ ស្ទើរតែពាក់កណ្ដាលធ្វើការផ្នែកដេរ (៤៦,៣%) ក្រៅពីនេះធ្វើការនៅក្នុងផ្នែកពិនិត្យគុណភាព កាត់ អ៊ុត បង្ហើយការ និងផ្នែកផ្សេងៗទៀត ។ ប្រហែលជា ៤៩% នៃកម្មករគឺជាសមាជិកនៃសហជីព ។

ជាមធ្យមកម្មករទាំងនោះមានបទពិសោធន៍ការងារចំនួន៣ឆ្នាំនៅក្នុងឧស្សាហកម្ម នៅពេលដែល៤៧,៣%មានបទពិសោធន៍តិចជាង៣ឆ្នាំ និង មួយចំនួនមានបទពិសោធន៍តិចជាង១០ឆ្នាំ ។ រូបភាពដែលឃើញថា មានកម្មករថ្មីៗ ចូលធ្វើការនៅក្នុងរោងចក្រ បើទោះបីជាឧស្សាហកម្មកាត់មានអាយុលើសពី១០ឆ្នាំក៏ដោយ គឺវាបញ្ជាក់ថាកម្មករកាត់ដេរ ជាទូទៅមិននៅធ្វើការនៅក្នុងវិស័យកាត់យូរអង្វែងឡើយ ។

ម្យ៉ាងវិញទៀត កម្មករបានធ្វើការនៅរោងចក្របច្ចុប្បន្នបានរយៈពេលជាមធ្យម ២,៥ ឆ្នាំ បើទោះជា ៤៨% (ឬ ១៤៥ នាក់) បានធ្វើការនៅរោងចក្របច្ចុប្បន្នមិនលើសពី១ឆ្នាំក៏ដោយ (សូមមើលរូបភាពទី៥) ។ ប្រាក់អតីតភាពការងារដែលតាមច្បាប់កំណត់ និយោជកត្រូវបង់ឱ្យកម្មករ[12] ក្នុងករណីកម្មករធ្វើការក្នុងរោងចក្របច្ចុប្បន្នតែប៉ុណ្ណោះ ។ ដូច្នេះ ទោះបីជាកម្មករមានបទពិសោធន៍ការងារ១០ឆ្នាំក៏ដោយ នៅពេលដែលគេចាកចេញទៅធ្វើការនៅរោងចក្រមួយផ្សេងទៀត នោះប្រាក់អតីតភាពការងារត្រូវបានកំណត់ឱ្យស្មើនឹងសូន្យវិញ ។

## រូបភាពទី ៥ : ចំនួនកម្មករទៅតាមចំនួនឆ្នាំនៃបទពិសោធន៍ការងារក្នុងរោងចក្របច្ចុប្បន្ន




ក្នុងរយៈពេលចុងក្រោយ ជាមធ្យម កម្មករទទួលបានប្រាក់ខែជាក់ស្តែង ៨៦,៨៨ដុល្លារក្នុង១ខែ បូករួមទាំងប្រាក់ខែគោល ប្រាក់ថែមម៉ោង និងប្រាក់រង្វាន់ដទៃទៀត ។ ប្រាក់ខែគោល (ដែលជាប្រាក់ឈ្នួលអប្បបរមា) មានកម្រិតលើសពាក់កណ្តាល (៥៨%) នៃប្រាក់ឈ្នួលជាក់ស្តែង ។ កម្មកររកបានប្រាក់ថែមម៉ោងជាមធ្យម ១៤,៥៥ដុល្លារ ដែលស្មើនឹង ១៧%នៃប្រាក់ឈ្នួលសរុប ។ ធាតុផ្សំផ្សេងៗទៀតនៃប្រាក់ឈ្នួលរបស់កម្មកររួមមាន ប្រាក់រង្វាន់ការងារទៀងទាត់ ប្រាក់អតីតភាពការងារ ប្រាក់ជួយទ្រទ្រង់ជីវភាព ប្រាក់ជំនាញ និង ប្រាក់ឧបត្ថម្ភផ្សេងៗ ។ កម្មករស្ទើរតែទាំងអស់បានលើកឡើងថា គេធ្វើការជាធម្មតា ៨ ម៉ោងក្នុង១ថ្ងៃ និង ៦ថ្ងៃក្នុង១សប្តាហ៍ ។

[12] If employed at factory for 1 year, receive $2 per month; 2 years, $3 per month; 3 years, $4 per month; 4 years or more, $5 per month (maximum).

## រូបភាពទី ៦ : ប្រាក់ឈ្នួលជាក់ស្តែង តាមធាតុផ្សំ




ប្រាក់ឈ្នួលជាក់ស្តែងសរុបគឺ ៨៦,៨៨ ដុល្លារក្នុង១ខែ

គិតតាមតំបន់ (សូមមើលរូបភាពទី៧) កម្មករនៅខេត្តព្រះសីហនុរកបានច្រើនជាងគេ (ជាមធ្យម៩០,១៧ដុល្លារក្នុង១ខែ), ឯកម្មករនៅខេត្តស្វាយរៀងរកបានតិចជាងគេបំផុត (៨២,៥៦ដុល្លារក្នុង១ខែ) ។ កម្មករដែលរកចំណូលបានខ្ពស់ជាងកម្រិតមធ្យម ច្រើនតែជា :

1) កម្មករដេរស៊ីប៉ុង : កម្មករដេរស៊ីប៉ុងរកបានជាមធ្យម ១០៧,៦០ដុល្លារក្នុង១ខែ ពេលនៅពេលដែលកម្មករធ្វើការធម្មតារកបាន ៨៣,០៣ ដុល្លារក្នុង១ខែ
2) កម្មករមានម៉ោងថែម : ចំពោះកម្មករដែលរកចំណូលបានលើសកម្រិតមធ្យម គឺកម្មករទាំងនោះទទួលបានចំណូលពីម៉ោងថែមចំនួន២៥ដុល្លារក្នុង១ខែ ។ ចំណែកកម្មករដែលរកចំណូលបានស្មើនឹងកម្រិតមធ្យម គេទាំងនោះទទួលប្រាក់ពីម៉ោងថែមត្រឹមតែ១៥ដុល្លារតែប៉ុណ្ណោះ នៅពេលដែលកម្មករទាំងឡាយដែលរកប្រាក់ចំណូលទាបជាងកម្រិតមធ្យម គេមិនមានប្រាក់ចំណូលពីថែមម៉ោងទាល់តែសោះ ។
3) ទាំងពីរខាងលើ : កម្មករដេរស៊ីប៉ុង និងមានថែមម៉ោង ។

### រូបភាពទី ៧ ៖ ប្រាក់ឈ្នួលជាក់ស្តែងគិតជាតម្លៃបច្ចុប្បន្ន តាមខេត្ត (ដុល្លារក្នុង១ខែ)




## ១១. ហេតុអ្វីបានជាចាំបាច់ត្រូវមានប្រាក់ឈ្នួលអប្បបរមា? (គោលបំណង)

ឆ្លងកាត់ការពិភាក្សាជាក្រុមជាមួយនឹងកម្មករ៥០នាក់នៅក្នុងខេត្តចំនួន ៥ មានការយល់ឃើញជា**រួមថា គោលបំណងចម្បងបំផុតនៃប្រាក់ឈ្នួលអប្បបរមា**គឺ ទី១) ដើម្បីធានាតម្រូវការចាំបាច់របស់កម្មករ និង អ្នកក្នុងបន្ទុក និង ២) ការពារការធ្លាក់ចុះនៃប្រាក់ឈ្នួលរបស់កម្មករ ។

### រូបភាពទី ៨ ៖ គោលបំណងតម្រូវឱ្យមានប្រាក់ឈ្នួលអប្បបរមា-តាមការយល់ឃើញរបស់កម្មករកាត់ដេរ

១) ធានាតម្រូវការចាំបាច់របស់កម្មករកាត់ដេរ និង អ្នកក្នុងបន្ទុក

២) ផ្តល់ការការពារប្រាក់ឈ្នួល

## គោលបំណងទី ១ : ធានាតម្រូវការចាំបាច់របស់កម្មករ និង អ្នកក្នុងបន្ទុក

> *"ខ្ញុំត្រូវតែផ្ញើលុយទៅផ្ទះ ។ បើខ្ញុំអាក់ខានមិនបានផ្ញើទៅ៣ខែ នោះឪពុកម្តាយខ្ញុំ នឹងហៅខ្ញុំទៅផ្ទះវិញ ។ ធ្វើការធ្វើអ្វី បើខ្ញុំ មិនអាចជួយគ្រួសារបានផងនោះ ។ ទៅធ្វើស្រែវិញល្អជាង ។"*
>
> កម្មករនៅខេត្តព្រះសីហនុ
>
> កិច្ចពិភាក្សាជាក្រុមនៅថ្ងៃទី ២៦ ខែ ខែកក្កដា ឆ្នាំ ២០០៩

ល័ក្ខខ័ណ្ឌទី១ ដែលមិនអាចជំទាស់បានគឺថា ប្រាក់ឈ្នួលអប្ប បរមាយ៉ាងហោចណាស់ ក៏ត្រូវបំពេញតម្រូវការចាំបាច់របស់ កម្មករដែរ ។ បន្ថែមលើនេះ កម្មករបានលើកឡើងថា ប្រាក់ឈ្នួល អប្បបរមាត្រូវតែបំពេញតម្រូវការចាំបាច់របស់ អ្នកក្នុងបន្ទុកផងដែរ ។ ដោយមិនគិតពីកម្មករចំណាកស្រុក ឬ រស់នៅក្នុងខេត្តទេ កម្មករទាំងអស់បានបញ្ជាក់ ឱ្យដឹងថា មូលហេតុ សំខាន់របស់គេដែលចូលមកធ្វើការក្នុងវិស័យកាត់ដេរគឺ ដើម្បីរកប្រាក់ជួយផ្គត់ផ្គង់គ្រួសារ ។ **នេះគឺជា បេសកម្ម និងកាតព្វកិច្ចដ៏សំខាន់បំផុតរបស់គេនៅក្នុងគ្រួសារ ។ ប្រសិនបើគេមិនអាចសម្រេចបេសកម្មនេះបានទេ គេត្រូវ តែត្រឡប់ទៅផ្ទះសម្បែងវិញ** ។ ដូច្នេះ ល័ក្ខខ័ណ្ឌចាំបាច់ក្នុងការធានាឱ្យមានកម្លាំងពលកម្មសម្រាប់វិស័យកាត់ដេររហូត គឺថា កម្មករត្រូវតែទទួលបានចំណូលយ៉ាងអន់ណាស់ក៏ សម្រាប់ដោះស្រាយតម្រូវការចាំបាច់របស់គេ និង អ្នកក្នុងបន្ទុក ដែរ ។

## គោលបំណងទី ២ : ការពារការធ្លាក់ចុះនៃប្រាក់ឈ្នួល

ដោយសារកត្តាជាច្រើន ប្រាក់ឈ្នួលរបស់កម្មករចាំបាច់ត្រូវតែត្រូវបានការពារ ។ ទី១ ការប្រកួតប្រជែង ដ៏តឹងតែងនៅក្នុង ឧស្សាហកម្មកាត់ដេរអាចនឹងជំរុញឱ្យម្ចាស់រោងចក្រឹតបណ្តឹងចំណាយ តាមរយៈកាត់បន្ថយប្រាក់ខែរបស់កម្មករ ជួនកាល ទាបជាងកម្រិតដែលកម្មករអាចរស់បាន នេះបើសិនជាពុំមានច្បាប់ការពារប្រាក់ខែទេ ។ ទី២ កម្មករកាត់ដេរសព្វថ្ងៃរស់នៅ អាស្រ័យទាំងស្រុងទៅលើប្រាក់ចំណូលបានពីថែមម៉ោង ។ ក្នុងករណីដែលគ្មានថែមម៉ោង ប្រាក់ចំណូលរបស់កម្មករមិន អាចគ្រប់គ្រាន់សម្រាប់ដោះស្រាយតម្រូវចាំបាច់របស់គេ ព្រមទាំងអ្នកក្នុងបន្ទុកទេ ។ នៅក្នុងស្ថានភាពដែលសេដ្ឋកិច្ចជួប វិបត្តិ ម្ចាស់រោងចក្របានកាត់បន្ថយ ឬ បំបាត់ការថែមម៉ោង (៤៥% នៃកម្មករ៣០០នាក់បានជួបប្រទះការធ្លាក់ចុះនៃ ម៉ោងថែមក្នុងឆ្នាំ ២០០៩, សូមមើលរូបភាពពី៩) ។ បើគ្មានចំណូលសម្រាប់ទប់ទល់ទេ កម្មករ និង គ្រួសាររបស់គេ នឹង ងាយធ្លាក់ចូលទៅក្នុងជីវភាពក្រីក្រ ។

### រូបភាពទី ៩ : តើមានបម្រែបម្រួលនៅក្នុងប្រាក់ថែមម៉ោងក្នុងឆ្នាំ២០០៩ខ្លះទេ?




នៅពេលជួបប្រទះនឹងវិបត្តិចំណូល ដោយសារតែការធ្លាក់ចុះនៃសេដ្ឋកិច្ច កម្មករបានបញ្ជាក់ពីដំណោះស្រាយរបស់គេដូចតទៅនេះ :

- **ប្រើប្រាស់ប្រាក់សន្សំកាលពីពេលមុន :** ការចាយប្រាក់សន្សំដែលមានតិចតួចធ្វើឱ្យកម្មករបាត់បង់សុវត្ថិភាព និង ងាយជួបបញ្ហា ពេលមានអាសន្នកើតឡើង ។
- **កាត់បន្ថយចំណាយផ្ទាល់ខ្លួន :** ជាពិសេស បរិភោគអាហារមានគុណភាពទាបជាងមុន ។ នេះធ្វើឱ្យកម្មករជួបប្រទះនូវបញ្ហាសុខភាព ដែលធ្វើឱ្យគេមិនមានកម្លាំងគ្រប់គ្រាន់ក្នុងការងារ ។
- **កាត់បន្ថយបញ្ញើទៅឱ្យអ្នកក្នុងបន្ទុក :** ក្នុងករណីដែលចាយលុយសន្សំអស់ កាត់បន្ថយចំណាយផ្ទាល់ខ្លួន ហើយនៅមិនគ្រប់គ្រាន់ទៀត នោះកម្មករនឹងកាត់បន្ថយប្រាក់បញ្ញើទៅផ្ទះជាជម្រើសចុងក្រោយ ។ ផលវិបាកគឺថា ជីវភាពគ្រួសាររបស់កម្មករកាត់ដេរក៏នឹងធ្លាក់ចុះទៅក្នុងភាពមិនគ្រប់គ្រាន់ដែរ ។

ដូច្នេះ ឥទ្ធិពលយូរអង្វែងនៃវិបត្តិសេដ្ឋកិច្ចមកលើប្រជាជនដែលរកចំណូលបានទាប ដូចជា កម្មករកាត់ដេរអាចមានសភាពធ្ងន់ធ្ងរ ។ ដោយសារអំណាចនៃសហជីពកម្មករកាត់ដេរក្នុងពេលបច្ចុប្បន្ន នៅមានភាពខ្សោយនៅឡើយ មានន័យថាការចរចាទាមទារប្រាក់ខែក្នុងកម្រិតរោងចក្រ ពិបាកនឹងទទួលបានជោគជ័យ ការកំណត់ប្រាក់ឈ្នួលអប្បបរមាដោយច្បាប់គឺជានយោបាយមួយដ៏ចាំបាច់បំផុត ក្នុងការជួយការពារកម្មករកាត់ដេរមិនឱ្យជួបវិបត្តិខ្លាំងដោយសារការ ប្រែប្រួលនៃសេដ្ឋកិច្ច ។

## ១២. តើកត្តាអ្វីខ្លះដែលគួរតែត្រូវដាក់បញ្ចូលក្នុងការគណនាប្រាក់ឈ្នួលអប្បបរមា? (កត្តាចាំបាច់)

ស្របទៅនឹងគោលបំណងរបស់កម្មករកាត់ដេរ ដែលតម្រូវឱ្យមានប្រាក់ឈ្នួលអប្បបរមា មាន**កត្តាសំខាន់បំផុតពីរដែលត្រូវដាក់បញ្ចូលទៅក្នុងការគណនាកម្រិតប្រាក់ឈ្នួលអប្បបរមា សម្រាប់ឧស្សាហកម្មកាត់ដេរកម្ពុជាៈ** ទី១-តម្រូវការចាំបាច់របស់កម្មករ និង ទី២-តម្រូវការចាំបាច់របស់អ្នកក្នុងបន្ទុក ។

**រូបភាពទី ១០ : កត្តាចាំបាច់តម្រូវឱ្យដាក់បញ្ចូលក្នុងប្រាក់ឈ្នួលអប្បបរមា**

១) តម្រូវការចាំបាច់របស់កម្មករ
២) តម្រូវការចាំបាច់របស់អ្នកក្នុងបន្ទុក

កត្តាចាំបាច់ទាំងពីរខាងលើនេះគឺជាល័ក្ខខ័ណ្ឌចាំបាច់ដែលត្រូវតែធ្វើឱ្យបាន ប្រសិនបើចង់រក្សាកម្លាំងពលកម្មឱ្យមានរហូតសម្រាប់ឧស្សាហកម្មកាត់ដេរ ក៏ដូចជាស្ថេរភាព និង កំណើននៃឧស្សាហកម្មកាត់ដេរ ជាពិសេសក្នុងពេលនៃវិបត្តិសេដ្ឋកិច្ច ។ ក្នុងករណីដែលកម្មករកាត់ដេរមិនអាចរកប្រាក់ចំណូលគ្រប់គ្រាន់ដើម្បីតម្រូវការរបស់គេ និង ផ្ញើទៅគ្រួសារ គេនឹងចេញពីការងារកម្មករកាត់ដេរទៅរកការងារនៅក្នុងវិស័យផ្សេងទៀត ឬក៏ទៅជួយធ្វើការគ្រួសារនៅឯស្រុក ។

### ១២.១ កត្តាចាំបាច់ទី ១ : តម្រូវការចាំបាច់របស់កម្មករកាត់ដេរ

គោលបំណងចម្បងនៃប្រាក់ឈ្នួលអប្បបរមា ដូចបានរៀបរាប់ខាងលើ គឺដើម្បីធានាថា កម្មករកចំណូលគ្រប់គ្រាន់ដើម្បីដោះស្រាយតម្រូវការចាំបាច់របស់គេ ។ ដូច្នេះ កត្តាចាំបាច់ដែលត្រូវដាក់បញ្ចូលក្នុងការគណនាប្រាក់ឈ្នួលអប្បបរមាគឺតម្រូវការចាំបាច់របស់កម្មករ ។ តាមរយៈការសម្ភាសន៏ តម្រូវការចាំបាច់របស់កម្មករកាត់ដេររួមមាន អាហារ សម្លៀកបំពាក់ ការស្នាក់នៅ ការធ្វើដំណើរ សុខភាព ការទំនាក់ទំនង ការសិក្សា និង ការថែទាំខ្លួនប្រាណ ។ **តម្រូវការចាំបាច់របស់កម្មករដែលផ្អែកលើខ្ទង់ចំណាយបច្ចុប្បន្ន វាគ្រាន់តែជារូបភាពមួយអាស្រ័យនឹងប្រាក់ចំណូលរបស់កម្មករតែប៉ុណ្ណោះ ប៉ុន្តែវាមិនឆ្លុះបញ្ចាំងពីតម្រូវការចាំបាច់ពិតប្រាកដ ដែលផ្អែកលើល័ក្ខខ័ណ្ឌសុខភាពឡើយ ។**

ក្នុងចំណោមកម្មករ៣០០នាក់ដែលត្រូវបានសម្ភាសន៍ ចំណាយជាមធ្យមទៅលើតម្រូវការចាំបាច់គឺ ៥៦,៩៥ ដុល្លារ (រូបភាពទី ១១) ។ គិតតាមតំបន់ កម្មករនៅក្នុងទីក្រុងភ្នំពេញ និង ខេត្តព្រះសីហនុ ចំណាយច្រើនជាងកម្រិតមធ្យមបន្តិច ដែលមាន៥៨,២ដុល្លារ និង ៥៧,២៨ដុល្លារ (រូបភាពទី១២) ។ កម្មករនៅខេត្តកណ្តាល ខេត្តកំពង់ឆ្នាំង និង ខេត្តស្វាយរៀង ផ្ទុយទៅវិញ ចំណាយតិចជាងកម្រិតមធ្យម ដែលក្នុងនោះកម្មករនៅខេត្តស្វាយរៀងចំណាយតិចជាងគេបំផុត (៥២,៣៨ដុល្លារក្នុងខែ) ។ យោងតាមការសម្ភាសន៍ ភាពខុសគ្នាក្នុងការចំណាយលើតម្រូវការចាំបាច់គឺ អាស្រ័យលើភាពខុសគ្នានៃប្រាក់ចំណូល មិនមែនភាពខុសគ្នានៃសុខភាពទេ ។ កម្មករទាំងឡាយដែលមានប្រាក់ចំណូលខ្ពស់ កម្មករទាំងនោះមានចំណាយទៅលើតម្រូវការចាំបាច់ច្រើន ។ កម្មករនៅក្នុងខេត្តស្វាយរៀងមានប្រាក់ឈ្នួលជាក់ស្តែងទាបបំផុត គឺ ៨២,៥៦ដុល្លារក្នុង១ខែ ចំណែកឯកម្មករនៅខេត្តព្រះសីហនុវិញមានប្រាក់ឈ្នួលខ្ពស់ជាងគេបំផុត គឺ ៩០,១៧ ដុល្លារក្នុង១ខែ ។

## រូបភាពទី ១១ : ចំណាយជាមធ្យមលើតម្រូវការចាំបាច់ តាមមុខចំណាយ (ដុល្លារក្នុង១ខែ)




ចំណាយសរុបលើតម្រូវការចាំបាច់គឺមានជាមធ្យម ៥៦,៩៩ដុល្លារក្នុង១ខែ

ចំណាយសរុបរបស់កម្មករលើអាហារមាន ៥៧% ក្នុងពេលដែលចំណាយផ្សេងៗក្រៅពីអាហារ ដូចជា ការស្នាក់នៅ ការធ្វើដំណើរ ការទំនាក់ទំនង ថាមពល-អគ្គិសនី ការថែទាំខ្លួនប្រាណ ការថែទាំសុខភាព, ការសិក្សា -ល- មាន៤៣% ។ យើងនឹងធ្វើការបង្ហាញបន្ថែមទៀតអំពីមុខចំណាយទាំងនេះ ឱ្យបានលំអិត ។

### រូបភាពទី ១២ : ចំណាយជាមធ្យមលើតម្រូវការចាំបាច់របស់កម្មករ តាមតំបន់ (ដុល្លារក្នុង១ខែ)




### ១២.១.១ អាហារ

ជាមធ្យមកម្មករចំណាយ ៣២,៧៩ដុល្លារក្នុង១ខែ ឬ ១,០៦ដុល្លារក្នុង១ថ្ងៃ លើអាហារ (សូមមើលរូបភាពទី១៣) ។ ចំណាយលើអាហារមាន៥៧,៦%នៃចំណាយសរុបលើតម្រូវការចាំបាច់ ។ តាមការវិភាគយើងឃើញថា ចំណាយទៅលើអាហារវាទាក់ទងខ្លាំងទៅនឹងកម្រិតនៃប្រាក់ចំណូលជាក់ស្តែង ដូចជា អ្នកដែលមានចំណូលខ្ពស់ គេចាយទៅលើអាហារក៏ច្រើនដែរ (សូមមើលរូបភាពទី១៤) ។ កម្មករនៅខេត្តព្រះសីហនុដែលរកចំណូលបានខ្ពស់ជាងកម្មករនៅខេត្តដទៃទៀត គឺ ៩០,១៧ ដុល្លារក្នុង១ខែ ចំណាយលើអាហារក៏ច្រើនជាងគេដែរ (៣៥,២៦ដុល្លារក្នុង១ខែ ឬ ៦១,៦%នៃចំណាយសរុប)។ ចំណែកឯ កម្មករនៅខេត្តស្វាយរៀងដែលរកចំណូលបានទាបជាងគេបំផុតគឺ ៨២,៥៦ដុល្លារក្នុង១ខែ ចំណាយតិចបំផុតលើអាហារ គឺ ៣០,៦៨ដុល្លារក្នុង១ខែ (៥៨,៦%នៃចំណាយសរុប) ។

## រូបភាពទី ១៣ : ចំណាយជាមធ្យមលើអាហារ តាមតំបន់ (ដុល្លារក្នុង១ខែ)




កំណត់សំគាល់ : តួលេខនៅក្នុងវង់ក្រចកជា % នៃចំណាយសរុបលើតម្រូវការចាំបាច់របស់កម្មករ

## រូបភាពទី ១៤ : ប្រាក់ឈ្នួលជាក់ស្ដែងគិតតាមថ្លៃបច្ចុប្បន្ន និង ចំណាយលើអាហារ តាមតំបន់ (ដុល្លារក្នុង១ខែ)



**នៅក្នុងកិច្ចពិភាក្សាជាក្រុម កម្មករត្រូវសួរថា តើចំណាយបច្ចុប្បន្នរបស់គេលើអាហារគ្រប់ គ្រាន់ ដែររឺទេ ។** *កម្មករម្នាក់នៅខេត្តកណ្តាល បាននិយាយថា :"ខ្ញុំចំណាយប្រហែលជា ៥,០០០ រៀលក្នុង១ថ្ងៃលើ អាហារ ។ វាសមល្មមនឹងប្រាក់ខែរបស់ខ្ញុំ ប៉ុន្តែវាមិនគ្រប់គ្រាន់សម្រាប់សុខភាពទេ ។ ខ្ញុំមានសមត្ថភាពត្រឹមតែទិញ ម្ហូបដែលមានគុណភាពអន់តែប៉ុណ្ណោះ ។ ខ្ញុំមិនអាចទិញម្ហូបដែលមានជីវជាតិខ្ពស់ ដូចជា ថ្លៃឈើបានទេ។"* នេះគឺជាការយល់ឃើញរបស់កម្មករទាំងអស់នៅក្នុងតំបន់ដែលយើងធ្វើការសិក្សាស្រាវជ្រាវ ។ កម្មករទាំងប្រុស និង ស្រីបាន បញ្ជាក់ថា ដើម្បីឱ្យមានសុខភាពល្អ គេត្រូវការប្រហែលជា ១០,០០០ រៀលក្នុង១ថ្ងៃ ។



កម្មករបានរក្សាបានចាយត្បិតត្បៀតលើអាហារ ដោយសារភាគច្រើនគេយកអង្ករមកពីផ្ទះ ។ ឧទាហរណ៍ កម្មករនៅខេត្តកំពង់ឆ្នាំង បាននិយាយឱ្យដឹងថា គេយកអង្ករពីផ្ទះក្នុង១ខែ១៥គ.ក្រ ដែលមានតម្លៃស្មើប្រហែលជា ៨ ដុល្លារ ហើយបរិភោគអស់ ½ គ.ក្រ ក្នុង១ថ្ងៃ ។

### ១២.១.២ ការស្នាក់នៅ

ក្នុងកម្មករ ១០ នាក់ មាន៨នាក់ជួលផ្ទះគេដើម្បីស្នាក់នៅ (សូមមើលតារាងទី៣) ។ កម្មករនៅទីក្រុងភ្នំពេញស្ទើរតែទាំងអស់ (៩០,៨%នៃកម្មករដែលត្រូវបានសម្ភាសន៍នៅក្នុងទីក្រុងភ្នំពេញ) ជួលផ្ទះដើម្បីស្នាក់នៅ ដោយចំណាយជាមធ្យម ៦,២៤ដុល្លារក្នុង១ខែ ដែលជាកម្រិតខ្ពស់បង្អស់ធៀបនឹងតំបន់ផ្សេងៗទៀត (សូមមើលរូបភាពទី១៥) ។ កម្មករភាគច្រើនបំផុតនៅខេត្តព្រះសីហនុ (៨៨%) និង នៅខេត្តកណ្តាល (៧៩,៣%) ក៏ជួលផ្ទះដើម្បីស្នាក់នៅដែរ ដោយចំណាយជាមធ្យម ៥,៨៦ និង ៤,១០ ដុល្លារ១មួយខែ ។ ចំណែកឯកម្មករភាគច្រើននៅខេត្តស្វាយរៀង និង ខេត្តកំពង់ឆ្នាំងរស់នៅក្នុងផ្ទះផ្ទាល់ខ្លួន លើកលែងតែកម្មករដែលរស់នៅឆ្ងាយពីរោងចក្រប៉ុណ្ណោះ ទើបជួលផ្ទះនៅក្បែរកន្លែងធ្វើការដើម្បីកាត់បន្ថយចំណាយលើការធ្វើដំណើរ ។

## តារាងទី ៣ : ចំនួនអ្នកត្រូវបានសម្ភាសន៍ដែលជួលបន្ទប់ស្នាក់នៅ

| តំបន់ | ចំនួន | % នៃអ្នកត្រូវបានសម្ភាសន៍ |
|---|---|---|
| ទីក្រុងភ្នំពេញ | ១៧៨ | ៩០,៨ |
| ខេត្តព្រះសីហនុ | ២២ | ៨៨,០ |
| គ្រប់តំបន់ | ២៤២ | ៨០,៧ |
| ខេត្តកណ្ដាល | ២៣ | ៧៩,៣ |
| ខេត្តស្វាយរៀង | ១១ | ៤៤,០ |
| ខេត្តកំពង់ឆ្នាំង | ៨ | ៣២,០ |

## រូបភាពទី ១៥ : ចំណាយជាមធ្យមលើការស្នាក់នៅ តាមតំបន់ (ដុល្លារក្នុង១ខែ)




កំណត់សំគាល់ : តួលេខនៅក្នុងវង់ក្រចកជា % នៃចំណាយសរុបលើតម្រូវការចាំបាច់របស់កម្មករ



មិនថាតំបន់ណា ឬខេត្តណាទេ ស្ថានភាពស្នាក់នៅ គឺប្រហាក់ប្រហែលគ្នា។ បន្ទប់ជាទូទៅមិនលើសពី១២ម² ដោយត្រូវចំណាយប្រហែលជា ២៥ ដុល្លារក្នុង១ខែ បូករួមទាំងថ្លៃទឹក តែមិនបូកថ្លៃភ្លើងទេ ។ ដើម្បីកាត់បន្ថយចំណាយលើការស្នាក់នៅ កម្មករ៣-៥នាក់ស្នាក់នៅជាមួយគ្នា ។ ជាទូទៅ នៅក្នុងបន្ទប់មិនមានកង្ហារទេ ពីព្រោះតែកម្មករមិនអាចលៃលកថ្លៃភ្លើងបានទេ ដែលនេះធ្វើឱ្យបន្ទប់ក្តៅ និង ហប់នៅពេលយប់ ។ កម្មករជាច្រើនបានត្អូញថា *"ពិបាកដេកពេលយប់ណាស់ ព្រោះក្តៅណាស់ ជាពិសេសនៅខែប្រាំង ។ ច្រើនយប់ដែរក្នុង១ខែៗ ខ្ញុំដេកមិនលក់ ហើយទៅធ្វើការអត់មានកម្លាំងកម្ហែង រហូតខ្ញុំឈឺ "*[13] ពេលពិភាក្សាក្នុងក្រុម កម្មករបានបញ្ជាក់ថា ស្ថានភាពរស់នៅនឹងល្អប្រសើរ ប្រសិនបើបន្ទប់មានសមាជិកតែ២នាក់ ហើយចែកគ្នាចេញថ្លៃបន្ទប់ ។ ប៉ុន្តែ គេមិនអាចលៃលកបែបនេះបានទេ ពីព្រោះបានប្រាក់ខែតិចពេក ។

### ១២.១.៣ ការធ្វើដំណើរ និង ការទំនាក់ទំនង

កម្មករចំណាយជាមធ្យម៥,៣៨ដុល្លារក្នុង១ខែលើការធ្វើដំណើរ និង ការទំនាក់ទំនង ដែលស្មើនឹង ៩,៤%នៃចំណាយសរុបលើតម្រូវការចាំបាច់ (ដូចមានបង្ហាញនៅក្នុងរូបភាពទី១៦)។ កម្មករនៅខេត្តកំពង់ឆ្នាំង ស្វាយរៀង និង ខេត្តកណ្តាល ចំណាយទៅលើការធ្វើដំណើរច្រើនជាងកម្រិតមធ្យម នៅពេលដែលកម្មករនៅក្នុងខេត្តព្រះសីហនុ និង ទីក្រុងភ្នំពេញក្រោមកម្រិតមធ្យម ។ ករណីនេះគឺ ដោយសារកម្មករនៅខេត្តកំពង់ឆ្នាំង ស្វាយរៀង និង ខេត្តកណ្តាល ច្រើនរស់នៅឯផ្ទះឆ្ងាយពីកន្លែងធ្វើការ ដែលតម្រូវឱ្យគេធ្វើដំណើរតាមរថយន្ត ។ ចំណែកកម្មករក្នុងទីក្រុងភ្នំពេញ និង ខេត្តព្រះសីហនុច្រើនតែជួលផ្ទះនៅក្បែរកន្លែងធ្វើការ ។

[13] Quote from worker in Sihanoukville during FGD on July 26, 2009.

## រូបភាពទី ១៦ : ចំណាយជាមធ្យមលើការធ្វើដំណើរ និង ការទំនាក់ទំនង តាមតំបន់ ( ដុល្លារក្នុង១ខែ )




កំណត់សំគាល់ : តួលេខនៅក្នុងវង់ក្រចកជា % នៃចំណាយសរុបលើតម្រូវការចាំបាច់របស់កម្មករ



នៅគ្រប់តំបន់ លក្ខណៈនៃមធ្យោបាយធ្វើដំណើរ ស្ថានភាពធ្វើដំណើរគឺដូចគ្នាទាំងអស់ ។ រថយន្តកូរ៉េ១តោនកន្លះដែលគ្មានកៅអីអង្គុយត្រូវបានប្រើជាមធ្យោបាយដឹកជញ្ជូនកម្មករ ។ តាមសំដីរបស់អ្នកបើកថយន្ត ១ជើងៗ គេដឹកកម្មករពី ៤០ ទៅ ៦០នាក់ ។ ថ្លៃជិះក្នុង១ខែៗសម្រាប់កម្មករម្នាក់ៗមានចាប់ពី ៧ ទៅ ១០ ដុល្លារក្នុង១ខែ ដោយរាប់បញ្ចូលទាំងថ្ងៃថែមម៉ោង និង ថ្ងៃអាទិត្យ ។ កម្មករជាទូទៅរស់នៅក្នុងចំងាយជាមធ្យម១០គ.មពីរោងចក្រ ។ នៅក្នុងខេត្តកំពង់ឆ្នាំង កម្មករត្រូវធ្វើដំណើររហូតដល់ ៣០គ.ម ទៅរោងច្រក ដែលនេះជាមូលហេតុធ្វើការឱ្យគេមាន ចំណាយខ្ពស់ជាងគេលើការធ្វើដំណើរ ។ ការដែលថ្លៃប្រេងឥន្ធនៈឡើងក្នុងឆ្នាំ២០០៨កន្លងមក ការធ្វើដំណើរក៏បានឡើង ថ្លៃស្របគ្នាដែរ ។

## ១២.១.៤ សម្លៀកបំពាក់

កម្មករចំណាយលើសម្លៀកបំពាក់ និងស្បែកជើង ជាមធ្យម៣,៥៨ដុល្លារក្នុង១ខែ ដែលស្មើនឹង៦,៣%នៃចំណាយសរុបលើតម្រូវការចាំបាច់ (សូមមើលរូបភាពទី១៧) ។ ភាពខុសគ្នានៅក្នុងចំណាយលើសម្លៀកបំពាក់រវាងតំបន់ និង តំបន់ គឺមានកម្រិតតិចតួចតែប៉ុណ្ណោះ (ត្រឹម0,៦៤ដុល្លារក្នុង១ខែ) ។

### រូបភាពទី ១៧ : ចំណាយជាមធ្យមលើសម្លៀកបំពាក់ តាមតំបន់ (ដុល្លារក្នុង១ខែ)




កំណត់សំគាល់ : តួលេខនៅក្នុងវង់ក្រចកជា % នៃចំណាយសរុបលើតម្រូវការចាំបាច់របស់កម្មករ

នៅក្នុងកិច្ចពិភាក្សាជាក្រុម កម្មករបានបញ្ជាក់ឱ្យដឹងថា គេទិញសម្លៀកបំពាក់ប្រហែលជា ១០សម្រាប់ក្នុង១ឆ្នាំ ។ គេចំណាយជាច្រើនទៅលើសម្លៀកបំពាក់សម្រាប់ ចូលឆ្នាំខ្មែរប្រពៃណីជាតិ បុណ្យភ្ជុំបិណ្ឌ និង ពិធីបុណ្យអុំទូក ដែលជាមធ្យម ៣0 ដុល្លារក្នុងបុណ្យម្តងៗ ។ ក្រៅពីបុណ្យប្រពៃណីពិសេសៗទាំងនេះ កម្មករទិញសម្លៀកបំពាក់រៀង២-៣ម្តង ដែលម្តងៗមិនលើសពី ១០ ដុល្លារទេ ។

## ១២.១.៥ សុខភាព

> *"ឥឡូវនេះ ខ្ញុំឈឺញឹកញាប់ជាងកាលពី២មុន ។ ខ្ញុំឈឺក្រពះព្រោះខ្ញុំមិនមានលទ្ធភាពទិញអាហារដែលមានគុណភាពល្អ និងដោយសារមានពេលតិចតួចសម្រាប់សម្រាកប៉ុណ្ណោះ បន្ទាប់ពីអាហារហើយ ។ ពេលសម្រាប់សម្រាកអាហារ គឺមានតែ៣០នាទីប៉ុណ្ណោះ ។"*
>
> កម្មករនៅខេត្តកណ្តាលនិយាយនៅក្នុងកិច្ចពិភាក្សាជាក្រុម កាលពីថ្ងៃទី១៣ខែសីហា ឆ្នាំ២០០៩ ។

ការចំណាយដើម្បីសុខភាពរបស់កម្មករ ដូចជា ការជួបជាមួយគ្រូពេទ្យ ការព្យាបាល និង ថ្នាំពេទ្យ គឺមានកម្រិត ប្រាក់ប្រហាក់ប្រហែលគ្នា ពីខេត្តមួយទៅខេត្តមួយប្រហែលជា ១,៧៥ ដុល្លារក្នុង១ខែ ជាមធ្យម (៣%នៃចំណាយសរុបលើតម្រូវការចាំបាច់ សូមមើលរូបភាពទី ១៨) ។ ការចំណាយទៅលើសុខភាពដែលមានកម្រិតទាបដូច្នេះ មិនមែនមានន័យថា កម្មករកាត់ដេរមានសុខភាពល្អ ហើយមិនត្រូវ ការសេវាសុខភាពនោះទេ ផ្ទុយទៅវិញ វាឆ្លុះបញ្ចាំង ពីចំនួនទឹកប្រាក់ដែលកម្មករអាចមានសមត្ថភាព ដោយសារតែ ប្រាក់ឈ្នួលរបស់គេមានកម្រិតទាប ។

ក្នុងពេលពិភាក្សាជាក្រុម កម្មករនៅគ្រប់ខេត្តទាំងអស់បានបញ្ជាក់ថា សុខភាពរបស់គេបានចុះខ្សោយបន្តិចម្តងៗ តាំងពីគេចាប់ផ្តើមធ្វើការនៅរោងចក្រមក ។ គេយល់ឃើញថា មានកម្មករប្រហែលជា៧០%ឈឺ ពីព្រោះតែជាតិគីមី ធូលី អង្គុយយូរ ពេលតិចតួចសម្រាប់អាហារ និង ពេលតិចតួចសម្រាប់បត់ជើង ។ កម្មករក៏បញ្ជាក់ផងដែរថា ៣០%ទៀតដែលមិនទាន់ឈឺ ក៏នឹងឈឺជាបន្តបន្ទាប់នៅក្នុងឆ្នាំក្រោយៗដែរ ។ ជាទូទៅ គេបានត្អូញត្អែរពីអាការ ដូចខាងក្រោម :

- **ឈឺក្បាល :** កម្មករឈឺក្បាល២-៣ថ្ងៃក្នុង១សប្តាហ៍ ។ គេអាចទទួលបានថ្នាំពីពេទ្យរោងចក្រម្តងក្នុង១ថ្ងៃ ។ ប្រសិនបើមិនគ្រប់គ្រាន់ទេ គេទៅទិញនៅឱសថស្ថានបន្ថែមទៀត ដោយចំណាយ ៣,០០០ រៀល (០,៧៥ដុល្លារ) ។
- **គ្រុនពោះវៀន :** នៅគ្រប់កន្លែង កម្មករស្ទើរតែទាំងអស់ជួបប្រទះជម្ងឺគ្រុនពោះវៀន បន្ទាប់ពីធ្វើការនៅរោងចក្របាន ១-២ឆ្នាំ ហើយត្រូវចំណាយម្តងពី ២០០,០០០ ទៅ ៤០០,០០០ រៀល (៥០-១០០ដុល្លារ) ។ កម្មករខ្លះមានជម្ងឺគ្រុនពោះវៀនលើសពីមួយដង ។

## រូបភាពទី ១៨ : ចំណាយជាមធ្យមលើការថែទាំសុខភាព តាមតំបន់ (ដុល្លារក្នុង១ខែ)




កំណត់សំគាល់ : តួលេខនៅក្នុងវង់ក្រចកជា % នៃចំណាយសរុបលើតម្រូវការចាំបាច់របស់កម្មករ

ការពិនិត្យលើចំណាយចាំបាច់លំអិតទៅតាមខ្ទង់នីមួយៗដូចខាងលើ បានធ្វើឱ្យយើងឃើញច្បាស់ថា កម្រិតនៃការចំណាយលើតម្រូវការចាំបាច់ គឺ អាស្រ័យទាំងស្រុងទៅលើប្រាក់ចំណូលបច្ចុប្បន្នរបស់គេ ដែលមានកម្រិតទាប ។ ដើម្បីចង់ដឹងថាកត្តាចាំបាច់ណាមួយដែលសំខាន់ជាងគេក្នុងការសម្រេចចិត្តរបស់កម្មករ ក្រុមស្រាវជ្រាវយើងបានសួរកម្មករអំពីអាទិភាពនៃតម្រូវការរបស់គេ (សូមមើលតារាងទី៤) ។

## តារាងទី ៤ : តើមុខចំណាយលើតម្រូវការចាំបាច់មួយណាដែលសំខាន់បំផុត?

| តំបន់ | អាទិភាពទីមួយ | អាទិភាពទីពីរ |
|---|---|---|
| ទីក្រុងភ្នំពេញ | អាហារ | សុខភាព |
| ខេត្តព្រះសីហនុ | សុខភាព | អាហារ |
| ខេត្តកណ្ដាល | អាហារ | សុខភាព |
| ខេត្តស្វាយរៀង | សុខភាព | អាហារ |
| ខេត្តកំពង់ឆ្នាំង | អាហារ | សុខភាព |

ប្រភព : ផ្អែកលើកិច្ចពិភាក្សាជាក្រុមជាមួយកម្មករ

កម្មករបានបញ្ជាក់ថា ការចំណាយលើអាហារគឺជាអាទិភាពទី១ នៅពេលដែលសុខភាពជាអាទិភាពទី២ ពីព្រោះគេយល់ឃើញថា ៖

- **អាហារ ៖** អាហារជួយឱ្យរក្សាសុខភាព និង កម្លាំងរបស់គេនៅក្នុងការងារ ។
- **សុខភាព ៖** គេនឹងមិនអាចធ្វើការបានទេ នៅពេលដែលគេឈឺ ។

## ១២.២កត្តាចាំបាច់ទី ២ ៖ តម្រូវការចាំបាច់របស់អ្នកក្នុងបន្ទុក

ជាមធ្យម គ្រួសាររបស់កម្មករមានសមាជិក៤នាក់ (បូករួមទាំងកម្មករខ្លួនឯង) ដែលក្នុងនោះ ២នាក់ជាអ្នករកចំណូល និង ២នាក់ទៀតជាអ្នកក្នុងបន្ទុក ។ ចំពោះអ្នកនៅក្នុងបន្ទុក យើងមានការលំបាកក្នុងការកំណត់ឱ្យច្បាស់លាស់អំពីកម្រិតនៃតម្រូវការចាំបាច់របស់គេ ដោយសារតែមានសេដ្ឋកិច្ចគ្រួសារជួយទំនុកបម្រុង ។ វិទ្យាស្ថានជាតិស្ថិតិ (NIS) មានតួលេខខ្លះអំពីចំណាយជាមធ្យមរបស់មនុស្សម្នាក់ៗនៅតាមជនបទ ក៏ប៉ុន្តែតួលេខទាំងនោះចាស់ ដែលមិនអាចបញ្ជាក់ពីចំណាយបច្ចុប្បន្នបានទេ ។ ជាដំណោះស្រាយករណីនេះ CIDS បានសួរកម្មករអំពីចំនួនប្រាក់បញ្ញើទាបបំផុតដែលគេត្រូវផ្ញើទៅផ្ទះក្នុង១ខែៗ ។ **កម្រិតប្រាក់បញ្ញើទាបបំផុតនេះ គឺជាផ្នែកមួយនៃទឹកប្រាក់ចំណាយលើតម្រូវការចាំបាច់របស់អ្នកក្នុងបន្ទុកនៃកម្មករកាត់ដេរ ។ វាគឺជាថវិកាកង្វះខាតរបស់គ្រួសារ ដែលកង្វះខាតនេះកម្មករកាត់ដេរត្រូវតែមានកាតព្វកិច្ចបំពេញរៀងរាល់ខែ** ។ តាមរយៈកិច្ចពិភាក្សាជាក្រុម កម្មករបានបញ្ជាក់ថា គេត្រូវតែផ្ញើ**១៥ដុល្លារក្នុង១ខែ** ជាមធ្យមទៅផ្ទះ ។

### រូបភាពទី ១៩ ៖ តម្រូវការចាំបាច់របស់អ្នកក្នុងបន្ទុក (ដុល្លារក្នុង១ខែ)

> តម្រូវការចាំបាច់របស់អ្នកក្នុងបន្ទុក = ប្រាក់បញ្ញើចាំបាច់អប្បបរមា = **១៥ ដុល្លារក្នុង១ខែ**

## ១៣. ប្រាក់ឈ្នួលអប្បបរមាត្រឹមត្រូវ

ក្រោយពីបានដឹងពីគោលបំណងរបស់កម្មករ ដែលតម្រូវឱ្យមានប្រាក់ឈ្នួលអប្បបរមា ព្រមទាំងដឹងអំពីកត្តាចាំបាច់ ដែលត្រូវដាក់បញ្ចូលទៅក្នុងការគណនា ដូចបានរៀបរាប់ខាងលើ យើងអាចបង្កើតរូបមន្តសាមញ្ញមួយ ដើម្បីគណនាប្រាក់ឈ្នួលអប្បបរមាត្រឹមត្រូវមួយ សម្រាប់ឧស្សាហកម្មកាត់ដេរកម្ពុជា (សូមមើលរូបភាពទី២០) :

### រូបភាពទី ២០ : រូបមន្តគណនាប្រាក់ឈ្នួលអប្បបរមា

ប្រាក់ឈ្នួលអប្បបរមា = តម្រូវការចាំបាច់របស់កម្មករ + តម្រូវការចាំបាច់របស់អ្នកក្នុងបន្ទុក

ខាងក្រោមនេះ យើងនឹងគណនាប្រាក់ឈ្នួលអប្បបរមាសម្រាប់ឧស្សាហកម្មកាត់ដេរ ដោយប្រើប្រាស់រូបមន្តខាងលើ គួបផ្សំនឹងព័ត៌មានដែលទទួលបានពីការសម្ភាសន៍ ព្រមទាំងកិច្ចពិភាក្សាជាមួយកម្មករកាត់ដេរជាក្រុម ។ យើងគណនាប្រាក់អប្បបរមាមានពីរកម្រិត ដោយផ្អែកលើសេណារីយ៉ូពីរផ្សេងគ្នា :

- សេណារីយ៉ូទី១ : ផ្អែកតាមចំណាយបច្ចុប្បន្នលើតម្រូវការចាំបាច់របស់កម្មករ
- សេណារីយ៉ូទី២ : បង្កើនថវិកាសម្រាប់អាហាររបស់កម្មករដល់កម្រិតមធ្យម

### *សេណារីយ៉ូទី ១ :ផ្អែកតាមចំណាយបច្ចុប្បន្ន*

លទ្ធផលនៃការស្រាវជ្រាវបង្ហាញថា បច្ចុប្បន្ន កម្មករចំណាយ**៥៦,៩៩ដុល្លារក្នុង១ខែលើតម្រូវការចាំបាច់** ដែលក្នុងនោះ **៣២,៨៦**ដុល្លារលើអាហារ និង **២៤,១៣**ដុល្លារទៀតលើតម្រូវការចាំបាច់ក្រៅពីអាហារ (ដូចជា ការស្នាក់នៅ ការធ្វើដំណើរ សុខភាព ។ល។) ។ **តម្រូវការចាំបាច់របស់អ្នកក្នុងបន្ទុកមានប្រហែលជា ១៥ ដុល្លារក្នុង១ខែ** ដែលជាចំនួនទឹកប្រាក់ទាបបំផុតដែលកម្មករត្រូវតែផ្ញើទៅ ឬ បើមិនដូច្នោះ គ្រួសាររបស់គេនឹងហៅគេទៅផ្ទះវិញ ។ ដោយប្រើតួលេខនេះជាមួយនឹងរូបមន្តខាងលើ យើងឃើញថា **ប្រាក់ឈ្នួលអប្បបរមា ត្រឹមត្រូវតាមសេណារីយ៉ូទី១ ស្មើនឹង ៧១,៩៩ដុល្លារក្នុង១ខែ** (ដូចបង្ហាញក្នុងរូបភាពទី២១) ។ *ប្រាក់ឈ្នួលអប្បបរមា កម្រិតនៃប្រាក់ឈ្នួលអប្បបរមា*

*នេះធានាថា កម្មករររក្សាបានកម្រិតចំណាយបច្ចុប្បន្នរបស់គេ ហើយក៏ធានាថា កម្មករមានសមត្ថភាពផ្ញើប្រាក់ទៅផ្ទះបានក្នុងកម្រិតមួយដែលចាំបាច់បំផុត ។*

### រូបភាពទី ២១ : ប្រាក់ឈ្នួលអប្បបរមាត្រឹមត្រូវ (សេណារីយ៉ូទី ១)

| | |
|---|---|
| ប្រាក់ឈ្នួលអប្បបរមា | = តម្រូវការចាំបាច់របស់កម្មករ + តម្រូវការចាំបាច់របស់អ្នកក្នុងបន្ទុក |
| | = ៥៦,៩៩ + ១៥,00 |
| | = **៧១,៩៩ ដុល្លារក្នុង១ខែ** |

### *សេណារីយ៉ូទី ២ : បង្កើនឱកាសសម្រាប់អាហាររបស់កម្មករដល់កម្រិតមធ្យម*

ដូចដែលបានបង្ហាញរួចមកហើយ ចំណាយបច្ចុប្បន្នរបស់កម្មករលើអាហារ (៣២,៨៦ដុល្លារក្នុង១ខែ ឬ ១,0៦ ដុល្លារក្នុង១ថ្ងៃ) គឺមិនគ្រប់គ្រាន់ទៅតាមតម្រូវការសុខភាពទេ ។ យោងតាមទិន្នន័យទទួលបានពីវិទ្យាស្ថានជាតិស្ថិតិ (NIS) មនុស្សម្នាក់ៗនៅទីក្រុងភ្នំពេញ ចំណាយជាមធ្យម ១,១៥ដុល្លារក្នុង១ថ្ងៃលើអាហារ ។ បើសិនជាយើងចង់ឱ្យកម្មករមានអាហារគ្រប់គ្រាន់ទៅតាមតម្រូវការសុខភាព នោះយើងគួរតែតំឡើងប្រាក់សម្រាប់ចំណាយលើអាហារ ឱ្យដល់កម្រិតមធ្យម ដូចដែលបានរកឃើញដោយវិទ្យាស្ថានជាតិស្ថិតិ ។ ក្នុងករណីដែលយើងគិតថា ចំណាយរបស់កម្មករទៅតម្រូវការចាំបាច់ក្រៅពីម្ហូបអាហារ និង តម្រូវការចាំបាច់របស់អ្នកក្នុងបន្ទុកមិនប្រែប្រួល នោះ**ប្រាក់ឈ្នួលអប្បបរមាដែលត្រឹមត្រូវតាមសេណារីយ៉ូទី២គឺមាន៧៤,៨៥ដុល្លារក្នុង១ខែ** ។ កម្រិតនៃ*ប្រាក់ឈ្នួលអប្បបរមានេះធានាថា កម្មករទទួលបានម្ហូបអាហារគ្រប់គ្រាន់ដូចប្រជាជនទូទៅក្នុងក្រុងភ្នំពេញ នៅពេលដែលគេនៅតែមានលុយផ្ញើទៅគ្រួសារប្រចាំខែក្នុងកម្រិតចាំបាច់ដដែល* (ដូច បង្ហាញនៅក្នុងរូបភាពទី២២) ។

រូបភាពទី ២២ : ប្រាក់ឈ្នួលអប្បបរមាត្រឹមត្រូវ (សេណារីយ៉ូទី ២)

| |
|---|
| ប្រាក់ឈ្នួលអប្បបរមា = តម្រូវការចាំបាច់របស់កម្មករ + តម្រូវការចាំបាច់របស់អ្នកក្នុងបន្ទុក<br>= ៥៩,៨៥ + ១៥,០០<br>**= ៧៤,៨៥ ដុល្លារក្នុង១ខែ** |

## ១៤. ការពិនិត្យឡើងវិញលើប្រាក់ឈ្នួលអប្បបរមា

តើរយៈពេលប៉ុន្មានឆ្នាំដែលតម្រូវឱ្យមានការពិនិត្យឡើងវិញលើប្រាក់ឈ្នួលអប្បបរមា ? តើកត្តាអ្វីខ្លះត្រូវយកមកពិចារណា? នៅប្រទេសជាច្រើន កត្តាចាំបាច់សម្រាប់ពិនិត្យឡើងវិញលើប្រាក់ឈ្នួលអប្បបរមារួមមាន ការប្រែប្រួលនៃចំណាយក្នុងការរស់នៅ ការប្រែប្រួលនៃចំណូល និង ការប្រែប្រួលនៃរបៀបរបបរស់នៅ ។ ប្រទេសមួយចំនួនពិនិត្យប្រាក់ឈ្នួលអប្បបរមាឡើងវិញរៀងរាល់ឆ្នាំ ប្រទេសខ្លះ៣ឆ្នាំម្តង ។ មានប្រទេសខ្លះ គេពិនិត្យឡើងវិញលើប្រាក់ឈ្នួលអប្បបរមា គឺនៅពេលដែលមានការបះបោរនៅក្នុងសង្គមតែប៉ុណ្ណោះ ។

យោងតាមការពិភាក្សាជាក្រុមជាមួយនឹងកម្មករនៅក្នុងខេត្តចំនួន ៥ កម្មករបានយល់ឃើញជារួមថា ប្រាក់ឈ្នួលអប្បបរមាគួរតែត្រូវបានពិនិត្យឡើងវិញ**រៀងរាល់ឆ្នាំ** ដោយគេមានមូលហេតុសំខាន់៣គឺ :

- **ការកើនឡើងក្នុងការចំណាយលើសុខភាព** : កម្មករបានបញ្ជាក់ថា សុខភាពរបស់គេចុះខ្សោយទៅៗពីមួយឆ្នាំទៅមួយឆ្នាំ ដែលនាំឱ្យគេត្រូវចំណាយលើសុខភាពកាន់តែច្រើន ។ កម្មករធ្លាក់ខ្លួនឈឺ១ឆ្នាំក្រោយពីចាប់ផ្តើមធ្វើការនៅរោងចក្រ ភាគច្រើនឈឺក្បាល និង គ្រុនពោះវៀន ។ ដូចបានរៀបរាប់ខាងលើ កម្មករឈឺក្បាលក្នុង១អាទិត្យពី២ទៅ៣ដង ។ ក្រោយធ្វើការក្នុងរោងចក្របានពី១ទៅ២ឆ្នាំ កម្មករមានជម្ងឺគ្រុនពោះវៀនដែលព្យាបាលម្តងៗត្រូវចំណាយពី៥០ដុល្លារទៅ១០០ដុល្លារ ។
- **ការប្រែប្រួលនៃស្ថេរភាពសេដ្ឋកិច្ច** : ជាពិសេសការប្រែប្រួលនៃថ្លៃទំនិញ និង ការប្រែប្រួលនៃម៉ាក្រូសេដ្ឋកិច្ច វាធ្វើឱ្យប្រាក់ចំណូលជាក់ស្តែងរបស់កម្មករបាត់បង់ស្ថេរភាព ។

- **ការប្រែប្រួលស្ថានភាពគ្រួសារ ៖** ពីមួយឆ្នាំទៅមួយឆ្នាំ ស្ថានភាពគ្រួសាររបស់កម្មករតែងតែផ្លាស់ប្តូរ ដោយសារតែគេស្ថិតក្នុងវ័យរៀបការ (ជាមធ្យមអាយុ២៤ឆ្នាំ)។ ការរៀបការ ឬ ការមានកូន គឺជាការប្រែប្រួលដែលធ្វើឱ្យមានការកើនឡើងនៃចំណាយ ។

## ១៥. ការប្រៀបធៀបប្រាក់ឈ្នួលអប្បបរមាជាមួយនឹងសូចនាករសំខាន់ៗ

ដើម្បីធានាថា ប្រាក់ឈ្នួលអប្បបរមានឹងមិនពង្រីកគម្លាតនៃប្រាក់ចំណូលនៅក្នុងសេដ្ឋកិច្ច និង សង្គម ហើយដើម្បីធានាថា ប្រាក់ឈ្នួលអប្បបរមាប្រាកដជាមានសារៈសំខាន់ និង ត្រឹមត្រូវទៅតាមបរបទនៃប្រទេស ជាទូទៅ គេតែងតែធ្វើការប្រៀបធៀបប្រាក់ឈ្នួលអប្បបរមាជាមួយនឹងសូចនាករសំខាន់ៗមួយចំនួន ដូចជា ខ្សែបន្ទាត់ភាពក្រីក្រ កម្រិតទូទៅនៃប្រាក់ឈ្នួល និង ផលិតភាពការងារ ។ ខាងក្រោមនេះ យើងនឹងធ្វើការប្រៀបធៀបប្រាក់ឈ្នួលអប្បបរមាដែលបានគណនាក្រោមសេណារីយ៉ូទី១ (៧១,៩៩ដុល្លារ ក្នុង១ខែ) ជាមួយនឹងសូចនាការទាំងនេះ ។

### ១៥.១ ខ្សែបន្ទាត់ភាពក្រីក្រ

ប្រាក់ឈ្នួលអប្បបរមាគឺជាឧបករណ៍ទូទៅ សម្រាប់នយោបាយកាត់បន្ថយភាពក្រីក្រ ។ ដូច្នេះកម្រិតប្រាក់ឈ្នួលត្រូវស្ថិតនៅផ្នែកខាងលើនៃខ្សែបន្ទាប់ភាពក្រីក្រ ដើម្បីធានាថាគោលនយោបាយសម្រេចគោលដៅ ។ យោងតាមក្រសួងផែនការ (សូមមើលរូបភាពទី២៣) ខ្សែបន្ទាត់ភាពក្រីក្រ[14]គឺ៣,២៥៨រៀលក្នុងប្រជាជនម្នាក់ៗ (ឬ 0,៨១ ដុល្លារ) នៅក្នុងទីក្រុងភ្នំពេញ, ២,៧0៥រៀល (ឬ0,៦៨ដុល្លារ) នៅទីប្រជុំជនដទៃទៀត និង ២,៤២៩រៀល (ឬ0,៦១ដុល្លារ) នៅជនបទ គិតតាមថ្លៃទំនិញឆ្នាំ២00៩ ។ ប្រាក់ឈ្នួលអប្បបរមាក្រោមសេណារីយ៉ូទី១ដែលស្មើនឹង ៧១,៩៩ដុល្លារក្នុង១ខែ ឬ ២,៣២ដុល្លារក្នុង១ថ្ងៃ គឺស្ថិតនៅផ្នែកខាងលើនៃខ្សែបន្ទាត់ភាពក្រីក្រ ដូច្នេះហើយវាឆ្លើយទៅនឹងគោលដៅនៃនយោបាយកាត់បន្ថយភាពក្រីក្រ ។

[14] Poverty line is adjusted to 2009 prices by CIDS using Consumer Price Index (CPI) figures from the National Institute of Statistics (NIS)

### រូបភាពទី ២៣ : ខ្សែបន្ទាត់ភាពក្រីក្រ និង ប្រាក់ឈ្នួលអប្បបរមា (ក្នុង១ថ្ងៃ-ថ្លៃដុល្លារបច្ចុប្បន្ន)




ប្រភព : ក្រសួងផែនការ វិទ្យាស្ថានជាតិស្ថិតិ និងវិទ្យាស្ថានកម្ពុជាដើម្បីសិក្សាការអភិវឌ្ឍន៍

ប្រាក់ឈ្នួលអប្បបរមាត្រឹមត្រូវមិនមែនមានតែតម្រូវការចាំបាច់របស់កម្មករទេ ថែមទាំងមានតម្រូវការចាំបាច់របស់អ្នកក្នុងបន្ទុកទៀតផង ។ នៅក្នុងប្រាក់ឈ្នួលអប្បបរមា៧១,៩៩ដុល្លារក្នុង១ខែ គឺមាន៥៦,៩៩ដុល្លារសម្រាប់ តម្រូវការចាំបាច់របស់កម្មករ ពោលគឺ ១,៨៤ក្នុង១ថ្ងៃ ។ ដូច្នេះ ប្រាក់ឈ្នួលអប្បបរមាត្រឹមត្រូវស្ថិតនៅផ្នែកខាងលើ នៃបន្ទាត់ភាពក្រីក្រ ។ ស្ថានភាពនេះ យើងត្រូវមានការប្រុងប្រយ័ត្ននៅក្នុងការអត្ថាធិប្បាយ ។ ការដែលកម្មករទទួលប្រាក់ឈ្នួលអប្បបរមាមានកម្រិតលើខ្សែបន្ទាត់ភាពក្រីក្រ មិនមានមានន័យថា កម្មករលែងក្រនោះទេ ។ បើយើងប្រៀបធៀបទៅនឹងមនុស្សទូទៅក្នុងទីក្រុងភ្នំពេញដែលគេចាយ ជាមធ្យម៣,០១ដុល្លារក្នុង១ថ្ងៃសម្រាប់តម្រូវការចាំបាច់ (១,១៥ដុល្លារសម្រាប់ម្ហូបអាហារ) នោះយើងឃើញថា កម្មករមានស្ថានភាពក្រជាង ពីព្រោះកម្មករមានសមត្ថភាពចាយទៅលើតម្រូវការចាំបាច់ត្រឹមតែ១,៨៤ដុល្លារក្នុង១ថ្ងៃប៉ុណ្ណោះ (១,០៦ដុល្លារសម្រាប់អាហារ) ។

## ១៥.២ ប្រាក់ឈ្នួលមធ្យម (GDP ម្នាក់ៗ)

ប្រាក់ឈ្នួលអប្បបរមាជាទូទៅត្រូវបានយកមកប្រៀបធៀបជាមួយនឹងប្រាក់ឈ្នួលមធ្យម ដើម្បីឱ្យដឹងថា តើប្រាក់ឈ្នួលអប្បបរមានោះអាចកាត់បន្ថយគម្លាតនៃប្រាក់ចំណូលនៅក្នុងសេដ្ឋកិច្ចដែរឬទេ ។ ក្នុងករណីដែលពុំមានព័ត៌មានអំពីប្រាក់ឈ្នួលមធ្យម គេយកប្រាក់ចំណូលម្នាក់មកប្រើជំនួស ។ ដូចបានបង្ហាញក្នុងរូបភាពទី២៤ ប្រាក់ឈ្នួលអប្បបរមាធៀប

ទៅនឹងប្រាក់ចំណូលម្នាក់ៗមាន ១១១% (គិតជាថ្លៃបច្ចុប្បន្ន) ឬ ១១៥% (គិតជាតម្លៃថេរ) ។ នៅក្នុងប្រទេសជាច្រើន ប្រាក់ឈ្នួលអប្បបរមាត្រូវបានកំណត់ជាទូទៅត្រឹមតែ ៣០% ទៅ ៦០% នៃប្រាក់ចំណូលម្នាក់ៗ បើទោះបីជានៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ វានៅចន្លោះពី ក្រោម៣០% ទៅលើសពី ១០០% នៃប្រាក់ចំណូលម្នាក់ៗក៏ដោយ ។[15]

ក្នុងករណីប្រទេសកម្ពុជា ការប្រៀបធៀបប្រាក់ឈ្នួលអប្បបរមា ជាមួយនឹងប្រាក់ចំណូលម្នាក់ៗ វាផ្តល់សារៈសំខាន់ទេ ដោយសារមានមូលហេតុពីរយ៉ាង ។ ទី១ គោលបំណងចម្បង ដែលតម្រូវឱ្យមានប្រាក់ឈ្នួលអប្បបរមានៅក្នុងវិស័យកាត់ដេរគឺមិនមែនដើម្បីកាត់បន្ថយគម្លាតនៃប្រាក់ចំណូលទេ ក៏ប៉ុន្តែ គឺដើម្បីធានាថាកម្មករកាត់ដេរមានប្រាក់គ្រប់គ្រាន់សម្រាប់ចំណាយលើតម្រូវការចាំបាច់របស់គេ និង សម្រាប់អ្នកក្នុងបន្ទុក ព្រមទាំងដើម្បីការពារការធ្លាក់ចុះនៃប្រាក់ឈ្នួល ។ ទី២ ប្រាក់ចំណូលម្នាក់ៗក្នុងប្រទេសកម្ពុជាបច្ចុប្បន្ន គឺទាបជាងចំណាយលើតម្រូវការចាំបាច់របស់កម្មករ និង អ្នកបន្ទុករួចហើយ ។ ដូច្នេះ បើយកប្រាក់ឈ្នួលអប្បបរមាឱ្យស្មើនឹងប្រាក់ចំណូលម្នាក់ៗ នោះមានន័យថា កម្មករកាត់ដេរមិនមានលុយគ្រប់គ្រាន់សម្រាប់ចំណាយលើតម្រូវការចាំបាច់របស់គេ និង អ្នកក្នុងបន្ទុកឡើយ ។

**រូបភាពទី ២៤ : ប្រាក់ឈ្នួលអប្បបរមា និង GDP ម្នាក់ៗ (ឆ្នាំ២០០៩)**




ប្រភព : វិទ្យាស្ថានជាតិស្ថិតិ និង វិទ្យាស្ថានកម្ពុជាដើម្បីសិក្សាការអភិវឌ្ឍន៍

[15] (ILO, 2009)

## ១៥.៣ តម្លៃបន្ថែមក្នុងកម្មករម្នាក់ៗ

ជាទូទៅ មានការបកស្រាយថា កម្មករមិនត្រូវទទួលបានប្រាក់ឈ្នួលលើសពីលទ្ធផលការងារដែលគេផ្តល់ឱ្យរោងចក្រទេ ព្រោះបើមិនដូច្នេះរោងចក្រនឹងដួលរលំ ។ លទ្ធផលដែលគេផ្តល់ឱ្យរោងចក្រត្រូវបានឱ្យឈ្មោះថា តម្លៃបន្ថែម ។ តម្លៃបន្ថែមនៃកម្មករម្នាក់ៗ គឺជាប្រភពនៃប្រាក់ចំណូលរបស់កម្មករ ។ ដូច្នេះ វាជារឿងសំខាន់ណាស់ ដែលត្រូវធ្វើការប្រៀបធៀបរវាងប្រាក់ចំណូលរបស់កម្មករជាមួយនឹងតម្លៃបន្ថែមរបស់កម្មករ ។

រូបភាពទី២៥ បង្ហាញពីការប្រៀបធៀបតម្លៃបន្ថែមនៃកម្មករម្នាក់ៗនៅក្នុងឧស្សាហកម្មកាត់ដេរ ជាមួយនឹងប្រាក់ឈ្នួលជាក់ស្តែងរបស់កម្មករ ។ ដូចបង្ហាញនៅក្នុងរូបភាព **យើងឃើញថា គម្លាតរវាងប្រាក់ឈ្នួល និង តម្លៃបន្ថែមនៃកម្មករម្នាក់ៗមានកម្រិតធំ ហើយមាននិន្នាការកាន់តែធំទៀត** ។ ក្នុងអំឡុងពេលពីឆ្នាំ ២០០៤ ដល់ ២០០៩ ប្រាក់ឈ្នួលជាក់ស្តែងរបស់កម្មករ មានជាមធ្យម២៤%នៃតម្លៃបន្ថែម; ក្នុងអំឡុងឆ្នាំ ២០០៧-២០០៩ វាបានធ្លាក់ចុះមកត្រឹម១៩% ។ បើយើងធ្វើការប្រៀបធៀប ប្រទេសចិនមាន ៣៤% និង ប្រទេសឥណ្ឌូនេស៊ីមាន ២៥% ក្នុងឆ្នាំ ២០០៨ មានន័យថា កម្មករនៅប្រទេសទាំងនោះទទួលចំណែកនៃផលការងារច្រើនជាងកម្មករនៅកម្ពុជា ។[16]

**រូបភាពទី ២៥ : តម្លៃបន្ថែម និង ប្រាក់ឈ្នួលជាក់ស្តែង ក្នុងឧស្សាហកម្មកាត់ដេរ (២០០៤-២០០៩)**




ប្រភព : វិទ្យាស្ថានជាតិស្ថិតិ ក្រសួងពាណិជ្ជកម្ម និងវិទ្យាស្ថានកម្ពុជាដើម្បីសិក្សាការអភិវឌ្ឍន៍, ផ : ព្យាករណ៍ទុកជាមុន

16 CIDS database, compiled from official sources in different countries

និន្នាការដូចមាននៅក្នុងរូបភាពទី២៥ គឺជានិន្នាការមួយមិនល្អទាល់តែសោះសម្រាប់កម្មករកាត់ដេរ ដែលនេះបង្ហាញពីភាពចាំបាច់ថា ប្រាក់ឈ្នួលអប្បបរមាត្រូវតែកែតម្រូវឱ្យទៅជាមធ្យោបាយមួយ ដើម្បីឱ្យកម្មករទទួលបានចំណែកសមរម្យពីការរីកចម្រើននៃសេដ្ឋកិច្ច ។ ការធ្លាក់ចុះនៃតម្លៃបន្ថែមរបស់កម្មករម្នាក់ៗក្នុងឆ្នាំ២០០៩ គឺដោយសារតែការធ្លាក់ចុះនៃសេដ្ឋកិច្ចក្នុងពិភពលោក មិនមែនដោយសារផលិតភាពការងារកម្មករធ្លាក់ចុះទេ ។

## ១៥.៤ កម្លាំងប្រកួតប្រជែង

មានមតិលើកឡើងថា ប្រាក់ឈ្នួលអប្បបរមានៅប្រទេសកម្ពុជា វាមានកម្រិតខ្ពស់ជាងនៅក្នុងប្រទេសប្រកួតប្រជែងដទៃទៀតរួចទៅហើយ ដូចជា ប្រទេសឥណ្ឌូនេស៊ី វៀតណាម និង បង់ក្លាដេស (ដូចបង្ហាញក្នុងរូបភាពទី១) ។ ដូច្នេះការកើនឡើងនៃ ប្រាក់ឈ្នួលអប្បបរមានឹងធ្វើឱ្យឧស្សាហកម្មកាត់ដេរនៅកម្ពុជាបាត់បង់កម្លាំងប្រកួតប្រជែង ។ ដើម្បីយល់ឱ្យកាន់តែច្បាស់ អំពីឥទ្ធិពលរបស់ប្រាក់ឈ្នួលអប្បបរមាមកលើកម្លាំងប្រកួតប្រជែង យើងត្រូវការចាំបាច់ពិនិត្យទៅលើទំហំនៃភាពចំណេញ ជាជាងពិនិត្យទៅលើកម្រិតប្រាក់ឈ្នួលអប្បបរមា ។ បើទោះបីជាប្រាក់ឈ្នួលអប្បបរមាខ្ពស់ជាងនៅប្រទេសដទៃទៀតដ៏ដោយ ប្រសិនបើទំហំនៃភាពចំណេញនៅតែធំ នោះម្ចាស់រោងចក្រនៅកម្ពុជាក៏ នៅតែយល់ឃើញថាប្រទេសកម្ពុជានៅតែកន្លែងផ្តល់ភាពចំណេញ និង គេមិនសម្រេចចិត្តប្តូរទីតាំងឡើយ ។

ដូចបង្ហាញនៅក្នុងរូបភាពទី២៦ ទំហំនៃភាពចំណេញនៅក្នុងឧស្សាហកម្មកាត់ដេរកម្ពុជា (៣១%) មានកម្រិតខ្ពស់ជាងយ៉ាងច្រើន បើធៀបទៅនឹង ឥណ្ឌា (១១,៨%), ឥណ្ឌូនេស៊ី (១០%), វៀតណាម (៦,៥%), ណេប៉ាល់ (៤,៤%) និង ចិន (ដែលមានកម្រិតទាបជាងគេបំផុតត្រឹមតែ៣,២%ប៉ុណ្ណោះ) ។ នេះបញ្ជាក់ថា ការកើនឡើងនៃប្រាក់ឈ្នួលអប្បបរមាក្នុងរូបភាពមួយសមរម្យ វានឹងមិនធ្វើឱ្យប្រទេសកម្ពុជាបាត់បង់ កម្លាំងប្រកួតប្រជែង ឬក៏លែងជាគោលដៅនៃអ្នកវិនិយោគទេ ។

## រូបភាពទី ២៦ : ទំហំនៃភាពចំណេញនៅក្នុងឧស្សាហកម្មកាត់ដេរ នៅប្រទេសមួយចំនួន (%)




ប្រភព : វិទ្យាស្ថានកម្ពុជាដើម្បីសិក្សាការអភិវឌ្ឍន៍ និង ប្រភពផ្សេងៗ (សូមមើលបញ្ជីឯកសារពិគ្រោះ)

ផ្ទុយទៅវិញ ការកើនឡើងនៃ**ប្រាក់ឈ្នួលអប្បបរមានឹងនាំឱ្យមានការកើនឡើងនៃផលិតភាពការងាររបស់កម្មករ** ។ នៅក្នុងកិច្ចពិភាក្សាជាក្រុម កម្មករបានបញ្ជាក់ថា បើសិនប្រាក់ឈ្នួលអប្បបរមាខ្ពស់ជាងមុន នោះគេនឹងមានអារម្មណ៍កក់ក្ដៅ ហើយនឹងមានទឹកចិត្តធ្វើការ ព្យាយាម និង អំណត់ជាងមុន ដែលនឹងមានលទ្ធផលប្រសើរជាងមុនសម្រាប់រោងចក្រ ។ ជាមួយគ្នានេះដែរ កម្មករបានលើកឡើងថា ការដែលមានប្រាក់ឈ្នួលអប្បបរមាត្រឹមត្រូវ នោះធ្វើឱ្យប្រាក់ចំណូលប្រចាំខែរបស់គេនឹងមិនអាស្រ័យទាំងស្រុងទៅលើ កម្លាំងសុខភាពរបស់គេ ។ មានន័យថា កម្មករទទួលបាននូវប្រាក់ឈ្នួលដែលមានការធានានៅកម្រិតអប្បបរមា បើទោះបីក្នុងករណីគេធ្លាក់ខ្លួនឈឺក៏ដោយ ។ ក្នុងករណីនេះ កម្មករនេះនឹងទទួលពេលគ្រប់គ្រាន់ដើម្បីសុខភាពល្អឡើងវិញ គេនឹងមានអារម្មណ៍ល្អនៅក្នុងការងារសម្រាប់រោងចក្រ ។

## ផ្នែកទី ៤ : សេចក្តីសន្និដ្ឋាន និង អនុសាសន៍

ការសិក្សាស្រាវជ្រាវនេះបានរួមចំណែកក្នុងការបង្កើតឱ្យមានវិធីសាស្ត្រច្បាស់លាស់មួយ ក្នុងការកំណត់ប្រាក់ឈ្នួលអប្បបរមាឱ្យបានត្រឹមត្រូវសម្រាប់ឧស្សាហកម្មកាត់ដេរកម្ពុជា និង សម្រាប់វិស័យដទៃទៀត ។ វិធីសាស្ត្រមាន ៣ ជំហ៊ានគឺ : ១) កំណត់គោលបំណងនៃប្រាក់ឈ្នួលអប្បបរមា ២) កំណត់កត្តាចាំបាច់ទាំងឡាយដែលត្រូវដាក់ទៅក្នុងប្រាក់ឈ្នួលអប្បបរមា និង ៣)សម្រួលរូបមន្តគណនាទៅតាមជំហ៊ានទី១ និង ទី២ ។ ជំហ៊ានទី១ និងទី២ ត្រូវតែគិតគូរអំពីស្ថានភាពជាក់ស្តែងរបស់កម្មករ ព្រមទាំងតម្រូវការរបស់គេ ដូច្នេះហើយ ត្រូវពឹងផ្អែកលើការសម្ភាសន៍ និង ពិភាក្សាជាមួយក្រុមគោលដៅ ។ តាមរយៈនេះ យើងអាចធានាថា ប្រាក់ឈ្នួលអប្បបរមាដែលរកឃើញ វានឹងត្រឹមត្រូវព្រមទាំងឆ្លុះបញ្ចាំងពីតម្រូវការចាំបាច់របស់កម្មករ ។

សម្រាប់ឧស្សាហកម្មកាត់ដេរកម្ពុជា ការសិក្សាស្រាវជ្រាវបានបង្ហាញថា :

- ប្រាក់ឈ្នួលអប្បបរមាបច្ចុប្បន្នដែលស្មើនឹង ៥០ ដុល្លារក្នុង១ខែ គឺមិនគ្រប់គ្រាន់សម្រាប់តម្រូវការចាំបាច់របស់កម្មករ និង អ្នកក្នុងបន្ទុកទេ ។ កម្មករត្រូវការតិចបំផុត ៧១,៩៩ ដុល្លារក្នុង១ខែ ក្នុងនោះ ៥៦,៩៩ ដុល្លារ បំពេញតម្រូវការចាំបាច់របស់កម្មករ និង ១៥ដុល្លារទៀតបំពេញតម្រូវការចាំបាច់របស់អ្នកក្នុងបន្ទុករបស់គេ ។
- ចាំបាច់ត្រូវពិនិត្យប្រាក់ឈ្នួលអប្បបរមាឡើងវិញជារៀងរាល់ឆ្នាំ ដើម្បីឆ្លើយតបទៅនឹងការផ្លាស់ប្តូរនៃស្ថានភាពសេដ្ឋកិច្ច (ដូចជា អតិផរណា) និង សុខភាពទ្រុតទ្រោមប្រចាំឆ្នាំ និងការប្រែប្រួលនៅក្នុងគ្រួសាររបស់កម្មករ ។
- នៅតំបន់ផ្សេងៗគ្នា វាមិនចាំបាច់តម្រូវការឱ្យមានប្រាក់ឈ្នួលអប្បបរមាខុសៗគ្នាទេ ពីព្រោះចំណាយសរុបសម្រាប់តម្រូវការចាំបាច់គឺស្មើគ្នាគ្រប់កន្លែង ។ ដូច្នេះ វាគួរតែមានប្រាក់ឈ្នួលអប្បបរមាតែមួយគត់ សម្រាប់ឧស្សាហកម្មកាត់ដេរទាំងមូល ។
- ក្នុងការតស៊ូមតិដើម្បីទាមទារប្រាក់ឈ្នួលអប្បបរមាត្រឹមត្រូវ វាគួរតែចាប់ផ្តើមពីកម្រិត៧១,៩៩ដុល្លារក្នុង១ខែសិន ពីព្រោះវាឆ្លុះបញ្ចាំងពីស្ថានភាពបច្ចុប្បន្នរបស់កម្មករ ។
- ការកើនឡើងនៃប្រាក់ឈ្នួលអប្បបរមានឹងមិនធ្វើឱ្យប្រទេសកម្ពុជាខាតបង់កម្លាំងប្រកួតប្រជែង ឬ លែងទាក់ទាញអ្នកវិនិយោគទេ ពីព្រោះទំហំចំណេញនៅក្នុងប្រទេសកម្ពុជា នៅខ្ពស់ជាងប្រទេសប្រកួតប្រជែង ដូចជា ឥណ្ឌូនេស៊ី វៀតណាម ណេប៉ាល់ និង ចិន ។ ផ្ទុយទៅវិញ ប្រាក់ឈ្នួលអប្បបរមា ដែលខ្ពស់នឹងធ្វើឱ្យផលិតភាពកាន់តែខ្ពស់ ពីព្រោះកម្មករម្នាក់ៗទទួលនូវអារម្មណ៍ធានាអំពីប្រាក់ចំណូល ។
- នៅក្នុងកិច្ចពិភាក្សាជាមួយក្រុមគោលដៅ កម្មករបានស្នើសុំឱ្យមានគណៈកម្មាធិការកំណត់ប្រាក់ឈ្នួលអប្បបរមាមួយ ដែលមានសមាជិកតំណាងឱ្យកម្មករ និង មន្ត្រីរដ្ឋាភិបាល ចូលរួមដោយស្របច្បាប់ក្នុងកិច្ចចរចា ។

## ឯកសារពិគ្រោះ


Business New Zealand (2002). *Annual Review of the Minimum Wage*. Report Submitted to the Labour Market Policy group, Department of Labour. Wellington, New Zealand.

International Labour Organization (2008). *Global Wage Report 2008/09*. Geneva: ILO.

International Labour Organization (2009). *Update on Minimum Wage Developments.* (Discussion Paper for Governing Body of the Committee on Economic and Social Policy GB.304/ESP/3). Geneva: ILO

Pember, R. & Dupré, M. (1997). Statistical Aspects of Minimum Wage Determination. Geneva: Bureau of Statistics, ILO. Retrieved from www.ilo.org on July 2009.

Prasanna, R. and Gowthaman, B. (2005). Sector Specific Living Wage for Sri Lankan Apparel Industry Workers. Report prepared for AlaRM for Wider Discussion.

Saget, C. (2004). *Minimum Wage – Does it Cut Poverty?*. Labour Education 2004/1-2, No. 134. Retrieved from www.ilo.org/public/english/dialogue/actrav/publ/134/17.pdf on July 2009

Shaheed, Z. (1994). Notes on Minimum Wage Fixing. Derived from "Minimum wages and low pay: An ILO perspective," International Journal of manpower, Vol. 15, No. 2/3, 1994 (pp. 49-61).


**ប្រភពសម្រាប់រូបភាពទី ២៦ :** ទំហំនៃភាពចំណេញនៃឧស្សាហកម្មកាត់ដេរនៅបណ្តាប្រទេសជ្រើសរើសមួយចំនួន (%) :


| | |
|---|---|
| Bangladesh: | Yamagata, T. (2007). Prospects for Development of the Garment Industry in Developing Countries: What Has Happened Since MFA-Phase Out?. IDE: Japan |
| Cambodia: | CIDS estimates based on data from Nathan Associations (2007). Factory Level Value Chain Analysis of Garment Industry in Cambodia; Yamagata, T. (2007). Prospects for Development of the Garment Industry in Developing Countries: What Has Happened Since MFA-Phase Out?. IDE: Japan |
| India: | Joshi, G (2002). *Garment Industry in South Asia: Rags or Riches?* ILO: New Delhi |
| Indonesia: | Bala Ramasamy and Matthew Yeung (2008). *Does China Have A Competitive Advantage in Low-End Garment Industry? A Case Study Approach.* |
| Vietnam | Vietnam Chamber of Commerce and Industry (Dec 3, 2008). *Vietnam's Textile Profit Margin Down 8 percent since WTO Membership.* *http://vibforum.vcci.com.vn/news_detail.asp?news_id=14696* |
| Nepal: | Joshi, G (2002). *Garment Industry in South Asia: Rags or Riches?* ILO: New Delhi |
| China: | China Statistics Bureau |